ខែធ្នូ ២០១៦

# សន្យាខ្យល់?

## ការសិក្សាពីការអភិវឌ្ឍលើទីតាំងបណ្តេញចេញទាំង៧៧ ក្នុងរាជធានីភ្នំពេញ




សមាគមធាងត្នោត

Sahmakum Teang Tnaut, a Cambodian Urban NGO

សមាគមធាងត្នោត

Sahmakum Teang Tnaut. a Cambodian Urban NGO

# សន្យាខ្យល់?


| | |
|---|---|
| កាលបរិច្ឆេទបោះពុម្ព | ខែធ្នូ ឆ្នាំ២០១៦ |
| បោះពុម្ពផ្សាយដោយ | អង្គការសមាគមធាងត្នោត |
| ក្រុមការងារស្រាវជ្រាវ | លោក យុន តុលា មន្ត្រីសហគមន៍ |
| | លោក ម៉ៅ វាសនា អ្នកហាត់ការ |
| | លោក សន សុក្រឹត អ្នកហាត់ការ |
| | លោក ច្រឹក សុភា អ្នកហាត់ការ |
| | កញ្ញា ដានីញ៉ែល ហ្គីល អ្នកស្ម័គ្រចិត្ត ផ្នែកស្រាវជ្រាវ |
| | កញ្ញា រ៉ូបេកា លីនតុន អតីតទីប្រឹក្សាកម្មវិធី |
| អ្នកវិភាគទិន្នន័យ | អ្នកស្រី គាំ ចាន់រស្មី មន្ត្រីស្រាវជ្រាវ |
| ទីប្រឹក្សាស្រាវជ្រាវ | កញ្ញា សារ៉ា រ៉ូស ជេនសុិន |
| ពិនិត្យ និងកែសម្រួល | កញ្ញា ជេសុីការ សុីខំបេ ទីប្រឹក្សាកម្មវិធី |

អង្គការសមាគមធាងត្នោតសូមថ្លែងអំណរគុណដល់ប្រជាពលរដ្ឋក្នុងទីតាំងទាំង៧៧ និងអ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមស្នូល ដែលបានរួមចំណែកផ្តល់នូវព័ត៌មានដ៏មានតម្លៃមិនអាចកាត់ថ្លៃបានក្នុងកិច្ចការស្រាវជ្រាវរបស់យើងខ្ញុំ។

ការសិក្សាស្រាវជ្រាវនេះគាំទ្រថវិការដោយ Heinrich Böll Stiftung កម្ពុជា

https://kh.boell.org/km

HEINRICH BÖLL STIFTUNG
CAMBODIA



**អង្គការសមាគមធាងត្នោត ខែធ្នូ ឆ្នាំ២០១៦**

ផ្ទះលេខ៧ ផ្លូវលេខ ៤៩៤ ភ្នំពេញ កម្ពុជា

ទូរសព្ទលេខ: (៨៥៥)២៣ ៥៥៥ ១៩៦៤

អុីម៉េល: info@teangtnaut.org

វេបសាយ: www.teangtnaut.org

ហ្វេសប៊ុក: https://www.facebook.com/teangtnaut/

# សន្យាខ្យល់ ?

សហគមន៍បុរីកីឡា ឆ្នាំ២០១១



ប្រភព៖ បិន វូឌ ឆ្នាំ២០១១

សហគមន៍បុរីកីឡា ឆ្នាំ២០១៦



ប្រភព៖ អង្គការសមាគមផាងត្នោត ឆ្នាំ២០១៦

សហគមន៍រីករាយ ឆ្នាំ២០១១



ប្រភព៖ បិន វូឌ ឆ្នាំ២០១១

សហគមន៍រីករាយ ឆ្នាំ២០១៦



ប្រភព៖ អង្គការសមាគមផាងត្នោត ឆ្នាំ២០១៦

# មាតិកា


**បញ្ជីរូបភាព** iii

**បញ្ជីតារាង** iii

**ពាក្យកាត់** iii

**បញ្ជីឧបសម្ព័ន្ធ** iv

**បញ្ជីឯកសារភ្ជាប់** iv

**ជំពូក ១ សេចក្តីផ្តើម** 1

**១.១. សេចក្តីផ្តើម** 1

**១.៣. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ** 6

**ជំពូក ២ វិធីសាស្ត្រនៃការស្រាវជ្រាវ** 8

**២.១. លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស** 8

**២.២. វិធីសាស្ត្រនៃការប្រមូលទិន្នន័យ** 8

**២.២.១. ប្រភពទិន្នន័យចំបង** 8

ក. ការសង្កេតទីតាំង 8

ខ. ការស្ទង់មតិសហគមន៍ 8

គ. កិច្ចសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ 9

**២.២.២. ទិន្នន័យបន្ទាប់បន្សំ** 10

**២.៣. វិសាលភាព និងដែនកំណត់** 10

**ជំពូក៣ ការរកឃើញ** 12

**៣.១. សេចក្តីសង្ខេបនៃទីតាំងបណ្តេញ** 12

៣.១.១. ករណីសិក្សា 14

**៣.២ លទ្ធផលរកឃើញ - តើការសន្យានឹងត្រូវបានរក្សាទុកដែរឬទេ ?** 17

**៣.២.១ លទ្ធផលរកឃើញពីការស្ទង់មតិដោយការសង្កេតទីតាំង** 17

៣.២.១.១. ការសិក្សាលើការអភិវឌ្ឍ ........ 17

៣.២.១.២ ការប្រើប្រាស់ទីតាំងនាពេលបច្ចុប្បន្ន ........ 18

**៣.២.២.ការរកឃើញក្នុងការស្ទង់មតិសហគមន៍** ........ 21

៣.២.២.១. ព័ត៌មានប្រជាសាស្ត្រ និងការយល់ដឹងទៅលើគម្រោងអភិវឌ្ឍន៍ ........ 21

៣.២.២.២ ស្ថានភាពរស់នៅ និងការផ្លាស់ប្តូរស្ថានភាពសង្គមសេដ្ឋកិច្ចបន្ទាប់ពីការបណ្តេញចេញ ឬការអភិវឌ្ឍ ........ 24

**ជំពូក ៤ សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........ 31

**៤.១. សេចក្តីសន្និដ្ឋាន** ........ 31

**៤.២. អនុសាសន៍** ........ 33

**ឧបសម្ព័ន្ធ** ........ 37

**ឯកសារបន្ថែម** ........ 51

## បញ្ជីរូបភាព

រូបភាពទី១៖ ទីតាំងបណ្ដេញចេញក្នុងរាជធានីភ្នំពេញ ........ 5

## បញ្ជីតារាង

តារាងទី១៖ ការពិពណ៌នាទីតាំងបានប្រើប្រាស់ ........ 21

តារាងទី២៖ ព័ត៌មានប្រជាសាស្ត្រ ........ 22

តារាងទី៣៖ មុខរបររបស់អ្នកចូលរួមក្នុងកិច្ចសម្ភាស ........ 23

តារាងទី៤៖ ការឆ្លើយតបអំពីស្ថានភាពរស់នៅរបស់អ្នកចូលរួម ........ 25

តារាងទី៥៖ ការឆ្លើយតបអំពីការទទួលបានសេវាសាធារណៈ និងសេវាសង្គម ........ 27

តារាងទី៦៖ ការឆ្លើយតបអំពីការទទួលបាននូវការចូលរួមនៅក្នុងសង្គម ........ 29

## ពាក្យកាត់

BKL........ សហគមន៍បឹងកក់

CDC........ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

FGD........ កិច្ចពិភាក្សាក្រុមស្នូល

GIZ........ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាល្លឺម៉ង់

IFC........ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ

KII........ កិច្ចសម្ភាសអ្នកផ្ដល់ព័ត៌មានសំខាន់ៗ

LICADHO........ សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

MLMUPC........ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

MoP........ ក្រសួងផែនការ

MPP........ សាលារាជធានីភ្នំពេញ

NALDR........ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

OHCHR........ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស

RGC........ រាជរដ្ឋាភិបាលកម្ពុជា

STT........ អង្គការសមាគមធាងត្នោត

UPWD........ អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១៖ វិធីសាស្រ្តក្នុងការកំណត់សហគមន៍ដែល "មិនមានឈ្មោះ" ទាំង៥:...................... 37

ឧបសម្ព័ន្ធ ២ក. លិខិតដាក់ទៅសាលារាជធានីភ្នំពេញ.......................................................... 39

ឧបសម្ព័ន្ធ ២ខ. លិខិតដាក់ទៅក្រសួងផែនការ ................................................................... 40

ឧបសម្ព័ន្ធ ២គ. លិខិតឆ្លើយតបពីក្រសួងផែនការ .............................................................. 41

ឧបសម្ព័ន្ធ ៣៖ ទំហំនៃការអភិវឌ្ឍក្នុងទីតាំងបណ្តេញចេញទាំង៧៧ ទីតាំង (ប្រភព៖ ការសង្កេត):42

ឧបសម្ព័ន្ធ៤៖ បញ្ជីឈ្មោះសហគមន៍ដែលបានចូលរួមក្នុងការស្ទង់មតិ (ប្រភព៖ ស្ទង់មតិសហគមន៍)........................................................................................................................ 43

ឧបសម្ព័ន្ធ ៥៖ ការសរុបលទ្ធផលទាំងអស់ពីការស្ទង់មតិសហគមន៍ (សំណួរពីលេខ១៧ ដល់ លេខ ៣១) ស្ថានភាពរស់នៅ និងការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គមក្រោយពីការបណ្តេញចេញ ឬការអភិវឌ្ឍ 44

ឧបសម្ព័ន្ធ៦៖ ការសង្ខេបពីតំបន់បណ្តេញចេញ (ប្រភព៖ អង្គការសមាគមធាងត្នោត - ការស្ទង់មតិសហគមន៍) ............................................................................................................... 46

## បញ្ជីឯកសារភ្ជាប់

ឯកសារភ្ជាប់ទី១៖ ការស្ទង់មតិបែបសង្កេត................................................................... 51

ឯកសារភ្ជាប់ទី២៖ ការស្ទង់មតិសហគមន៍ កាស្រាវជ្រាប់លំនៅដ្ឋាន ......................................... 54

ឧបសម្ព័ន្ធទី៣៖ សំណួរសម្រាប់កិច្ចពិភាក្សាក្រុម ..................................................................... 57

ឧបសម្ព័ន្ធទី៤៖ សំណួរសម្រាប់សម្ភាសអង្គការអភិវឌ្ឍន៍ស្ត្រីក្នុងទីក្រុង....................................... 58

ឧបសម្ព័ន្ធទី៥៖ សំណួរសម្រាប់សម្ភាសជាមួយអង្គការលីកាដូ................................................. 60

# ជំពូក ១ សេចក្តីផ្តើម

## ១.១. សេចក្តីផ្តើម

រាជធានីភ្នំពេញគឺជាទីក្រុងមួយដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស តាមរយៈការអភិវឌ្ឍទីក្រុង។ ក្នុងឆ្នាំ ១៩៩៨ មានប្រជាជនកម្ពុជាចំនួនម្នាក់ក្នុងចំណោមមនុស្ស២០នាក់បានមករស់នៅក្នុងរាជធានីភ្នំពេញជារៀងរាល់ថ្ងៃ។ ក្នុងរយៈពេលបួនឆ្នាំ ស្ថិតិនេះបានបង្ហាញថា មនុស្សម្នាក់ក្នុងចំណោមមនុស្ស១០នាក់បានមករស់នៅក្នុងធានីភ្នំពេញជារៀងរាល់ថ្ងៃ[1]។ នៅចន្លោះឆ្នាំ ១៩៩៨ និងឆ្នាំ២០០៨ ចំនួនប្រជាជនក្នុងរាជធានីភ្នំពេញបានកើនឡើងជាងពីរដង គឺកើនឡើងពី ៥៦៧,៨៦០ នាក់ ទៅ ១,២៣៧,៦០០ នាក់[2]។ ទីក្រុងរណបចំនួនប្រាំមួយកំពុងត្រូវបានអភិវឌ្ឍនៅជុំវិញរាជធានីភ្នំពេញ ហើយអគារខ្ពស់ៗជាច្រើនកំពុងរីកដូចផ្សិត ខណៈអគារខ្លះកំពុងត្រូវបានសាងសង់បន្ថែម។ ក្នុងរយៈពេល៥ឆ្នាំកន្លងមក ព្រំប្រទល់ខណ្ឌត្រូវបានផ្លាស់ប្តូរនៅក្នុងគោលបំណងដើម្បីបន្ធូរបន្ថយបន្ទុករដ្ឋបាលដែលបណ្តាលមកពីការពង្រីកទីក្រុង ជាមួយនឹងការកើនឡើងចំនួនខណ្ឌពី៨ទៅ១២ខណ្ឌ[3]។ លើសពីនេះទៅទៀត មានព័ត៌មានជាច្រើនបានបញ្ជាក់ថានឹងមានផែនការពង្រីកព្រំប្រទល់ទីក្រុងបន្ថែមទៀត[4]។ ខណៈពេលដែលទីក្រុងនេះកំពុងតែមានការអភិវឌ្ឍបែបនេះ វាបានជម្រុញឱ្យមានតម្រូវការដីធ្លីកើនឡើងសម្រាប់ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងសាធារណៈ។ ទន្ទឹមនឹងនេះ រាជធានីភ្នំពេញ ក៏ឃើញមានការកើនឡើងនៃការបណ្តេញចេញពីដីធ្លីនៅជុំវិញទីក្រុងផងដែរ ជាពិសេសតំបន់ដែលប្រជាសហគមន៍ក្រីក្ររស់នៅ។ ទោះបីជាមានការផ្សព្វផ្សាយជាច្រើនទាក់ទងទៅនឹងការបណ្តេញចេញនៅក្នុងសហគមន៍បុរីកីឡា ឬសហគមនបឹងកក់ក៏ដោយ តែតាមការពិតមានសហគមន៍ជាច្រើនផ្សេងទៀតទទួលរងការបណ្តេញចេញដោយបង្ខំ។

នៅក្នុងឆ្នាំ២០១១ អង្គការសមាគមធាងត្នោតបានធ្វើការសិក្សាស្រាវជ្រាវមួយទាក់ទងទៅនឹងការកើនឡើងនៃការបណ្តេញចេញដោយបង្ខំនៅក្នុងរាជធានីភ្នំពេញ ដោយបានកំណត់ទីតាំង នៃការបណ្តេញចេញទាំង៧៧។ មូលហេតុនៃការបណ្តេញចេញនេះ សាលារាជធានីភ្នំពេញ និងរាជ រដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ថា គឺដើម្បីអភិវឌ្ឍតំបន់ពាណិជ្ជកម្ម និងកែលម្អសោភ័ណភាពទីក្រុង[5]។

---

[1] MOP, Ministry of Planning. (2012). Migration in Cambodia: Report of the Cambodian Rural Urban Migration Project (CRUMP). Retrieved from: http://www.mop.gov.kh/LinkClick.aspx?fileticket=LrGGcGoNsXY%3D&tabid=213&mid=687
[2] *Ibid.*
[3] Khuon, N. (2013, December 18). Three New Districts in Phnom Penh Approved. The Cambodia Daily. Retrieved from: https://www.cambodiadaily.com/archives/three-new-districts-in-phnom-penh-approved-49424/
[4] Kang, S. (2015, 21 March). Phnom Penh Municipality Plans City Expansion. The Cambodia Daily. Retrieved from: https://www.cambodiadaily.com/archives/phnom-penh-municipality-plans-city-expansion-80500/
[5] Bristol, G. (2007). Cambodia: the struggle for tenure. Retrieved from: http://unhabitat.org/wpcontent/uploads/2008/07/GRHS.2007.CaseStudy.Tenure.Cambodia.pdf; OHCHR, Office of the United Nations High Commissioner for Human Rights. (2010). Eviction and Resettlement in Cambodia Human Costs, Impacts and Solutions. Retrieved from: http://cambodia.ohchr.org/WebDOCs/DocProgrammes/Resettlement_Study-28_Feb_2012_Eng.pdf

នេះបញ្ជាក់ឱ្យឃើញថា ការអភិវឌ្ឍទាំងនេះនឹងនាំមកនូវកំណើនសេដ្ឋកិច្ច និងធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញកាន់តែប្រសើរឡើង ចំណែកឯការវិភាគទៅលើផលប៉ះពាល់ និងផលប្រយោជន៍ ត្រូវបានធ្វើឡើងយ៉ាងហ្មត់ចត់ និងច្បាស់លាស់មុននឹងធ្វើការអភិវឌ្ឍទីក្រុង។ រាល់សេចក្ដីសម្រេចចិត្តក្នុងការបណ្ដេញប្រជាពលរដ្ឋចេញពីដីធ្លី និងលំនៅដ្ឋានរបស់ពួកគេដើម្បី ឱ្យការអភិវឌ្ឍបានដំណើរការទៅរលូននៅពេលនោះ គឺត្រូវបានគេសន្មតថាផលប្រយោជន៍ដែលបានមកពីការបណ្ដេញនេះ ច្រើនជាងផលប៉ះពាល់មកលើប្រជាពលរដ្ឋ។ ប៉ុន្តែអស់រយៈពេលប្រាំឆ្នាំមកហើយ អ្វីដែលយើងមិនដឹងនោះគឺថា តើការបណ្ដេញចេញនេះពិតជាផ្ដល់ផលប្រយោជន៍ច្រើនជាងផលវិបាក ឬយ៉ាងណា។

មានការសិក្សាស្រាវជ្រាវមួយបង្ហាញពីផលប៉ះពាល់ធ្ងន់ធ្ងរជាច្រើន ទៅលើជីវភាពប្រជាសហគមន៍ក្រីក្រ ដែលបណ្ដាលមកពីការបណ្ដេញចេញដោយបង្ខំ[6]។ ការសិក្សាស្រាវជ្រាវមួយចំនួនបានលើកឡើងថាអ្នកត្រូវបានគេបណ្ដេញចេញ ត្រូវបានយកទៅរស់នៅក្នុងតំបន់តាំងទីលំនៅថ្មីដែលមានចម្ងាយឆ្ងាយពីកន្លែងដើមរបស់ពួកគេ[7]។ ការបណ្ដេញចេញនេះបានធ្វើឱ្យជីវភាពរស់នៅរបស់ពួកគេកាន់តែលំបាកជាងមុនថែមទៀត។ បញ្ហាជារួមដែលកើតមានឡើងនៅក្នុងតំបន់តាំងទីលំនៅថ្មី មានដូចជា កង្វះខាតទឹកស្អាត គ្មានអគ្គីសនី និងគ្មានអនាម័យ ពិបាកក្នុងការទទួលបានសេវាកម្មសុខាភិបាល និងពិបាកទៅសាលារៀនជាដើម។ តំបន់តាំងទីលំនៅថ្មីដែលឆ្ងាយ បណ្ដាលឱ្យមានការកើនឡើងនៃតម្លៃប្រើប្រាស់នានា ពីព្រោះពួកគេបង្ខំចិត្តប្រើប្រាស់ទឹកភ្លើងពីក្រុមហ៊ុនឯកជន ដោយសារតែទឹកភ្លើងរដ្ឋមិនអាចទៅដល់។ អ្នកខ្លះបានបាត់បង់ការងារ ដោយសារតែកន្លែងដែលគេរស់នៅឆ្ងាយពីទីក្រុងពេក ហើយត្រូវចំណាយច្រើនសម្រាប់ថ្លៃធ្វើដំណើរទៅមកធ្វើការងារនៅទីក្រុងវិញ។ ចំណូលរបស់ពួកគេធ្លាក់ចុះ ដោយសារមិនសូវមានឱកាសការងារនៅក្នុងតំបន់បណ្ដេញចេញ។ ការបណ្ដេញចេញដោយបង្ខំនេះក៏ប៉ះពាល់ដល់សុខភាពផ្លូវចិត្តផងដែរ។ តាមការសិក្សាស្រាវជ្រាវក្នុងឆ្នាំ២០១៣របស់អង្គការស្ត្រីខ្មែរបានរកឃើញថា[8] បន្ទាប់ពីការបណ្ដេញចេញ ស្ត្រីដែលរងគ្រោះដោយការបណ្ដេញចេញដោយបង្ខំ[9] មានការពិបាកចិត្តជាងមុន បារម្ភច្រើន សម្រាលមិនសូវលក់ អស់កំលាំង និងការផ្ដោតអារម្មណ៍លើអ្វីមួយបានធ្លាក់ចុះជាងមុន។ ការសិក្សាស្រាវជ្រាវនេះក៏បានរកឃើញពីសញ្ញាណនៃជម្ងឺថប់អារម្មណ៍ ការតានតឹងផ្លូវចិត្ត ធ្លាក់ទឹកចិត្ត ភ័យខ្លាច ហើយស្ត្រីមួយចំនួនមានគំនិតចង់សម្លាប់ខ្លួនក៏មាន។

---

[6] *Ibid*.

[7] Mgbako, C., Gao, R., Joynes, E., Cave, A. and Mikhailevich, J. (2010). Forced Eviction and Resettlement in Cambodia: Case Studies from Phnom Penh. Wash. U. Global Stud. L. Rev. 39, 9(1).; Sahmakum Teang Tnaut, (2012). Resettling Phnom Penh: 54 – and counting?. Facts and Figures Report 21. Phnom Penh.

[8] Strey Khmer Organization. (2013). They took my land, they took my life: A report on the psychosocial impacts of land and evictions on women in Cambodia. Phnom Penh, Cambodia. Retrieved from: https://streykhmer.files.wordpress.com/2013/02/sko-summary-report-final-27-02-2013.pdf

[9] It should be noted that this study looked at evictees in provincial areas as well as in Phnom Penh.

សម្រាប់រាជធានីភ្នំពេញ ដូចមិនសូវឃើញមានផលប្រយោជន៍ច្រើនសោះ ដែលទទួលបានពីការអភិវឌ្ឍនៅក្នុងតំបន់បណ្តេញចេញទាំងនេះ។ សេដ្ឋកិច្ចប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ កើនឡើងជាមធ្យម៧% នៅក្នុងចន្លោះឆ្នាំ១៩៩៣ និងឆ្នាំ២០១៣ ដែលវិស័យទេសចរណ៍ ឧស្សាហកម្មកាត់ដេរ ការនាំអង្ករចេញ និងសំណង់បានរួមចំណែកឱ្យមានកំណើនសេដ្ឋកិច្ច[10]។ ប៉ុន្តែ នៅក្នុងរបាយការណ៍របស់ធនាគារពិភពលោកចេញផ្សាយនៅក្នុងឆ្នាំ២០១៥ បានបង្ហាញថាវិស័យទេសចរណ៍ ឧស្សាហកម្មកាត់ដេរ និងកសិកម្មបានធ្លាក់ចុះ ចំណែកឯវិស័យសំណង់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យមានកំណើនសេដ្ឋកិច្ចកម្ពុជា[11]។ នេះបង្ហាញពីផលចំណេញភ្លាមៗប្រកបដោយសក្តានុពល ក្នុងការស្វែងរកដីធ្លីសម្រាប់អភិវឌ្ឍន៍ក្នុងរាជធានីភ្នំពេញ ប៉ុន្តែ មិនមានភស្តុតាងណាបានបញ្ជាក់អំពីផលចំណេញនេះឡើយ។ លើសពីនេះទៅទៀត វាមិនបានឆ្លើយតបទៅនឹងចម្ងល់នានា ទាក់ទៅនឹងផលប្រយោជន៍រយៈពេលវែងសម្រាប់រាជធានីភ្នំពេញ និងប្រជាពលរដ្ឋដែលទទួលបានពីការអភិវឌ្ឍនៅក្នុងតំបន់បណ្តេញចេញនោះនៅឡើយ។

បើនិយាយពីការអភិវឌ្ឍក្រៅពីរាជធានីភ្នំពេញវិញ ការបែងចែកដីធ្លីសម្រាប់សហគ្រាសពាណិជ្ជកម្ម មិនបានផ្តល់ផលប្រយោជន៍រយៈពេលវែងដល់ប្រទេសកម្ពុជាដូចការរំពឹងទុកនោះទេ។ ក្នុងខែមេសា ឆ្នាំនេះ មានសេចក្តីរាយការណ៍មួយថា ដីសម្បទានសេដ្ឋកិច្ច (ជាយន្តការមួយដែលរដ្ឋាភិបាលបានជួលដីសម្រាប់អភិវឌ្ឍន៍ដំណាំកសិពាណិជ្ជកម្ម) បានផ្តល់ចំណូលជូនរដ្ឋត្រឹមតែចំនួន៥លានដុល្លាអាមេរិកប៉ុណ្ណោះក្នុងឆ្នាំ២០១៥ ដោយសារតែអសមត្ថភាពក្នុងការប្រមូលពន្ធ និងអំពើពុករលួយ[12]។ លើសពីនេះទៅទៀត ជាក់ស្តែង ខណៈដែលតំបន់បណ្តេញចេញខ្លះត្រូវបានអភិវឌ្ឍឡើងវិញយ៉ាងពេញលេញ តំបន់ផ្សេងទៀតមានសកម្មភាពសាងសង់ខ្លះ ចំណែកឯតំបន់មួយចំនួនទៀតគឺមិនទាន់មានការអភិវឌ្ឍទាល់តែសោះ។ នេះវាមិនឆ្លើយតបទៅនឹងអ្វីដែលលើកឡើងថា ការអភិវឌ្ឍបានរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចទីក្រុងភ្នំពេញរីកចម្រើន និងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងទីក្រុង ទាំងក្នុងរយៈពេលវែង និងរយៈពេលខ្លីនោះទេ។ ប៉ុន្តែ ថ្មីៗនេះពុំមានទិន្នន័យជាក់លាក់ណាមួយ បានបញ្ជាក់ពីការអភិវឌ្ឍនៅក្នុងទីតាំងដែលត្រូវបានគេបណ្តេញចេញនោះទេ ដែលនេះធ្វើឱ្យពិបាកក្នុងការវិភាគលើអំណះអំណាងទាំងនេះ។

ការសិក្សាស្រាវជ្រាវនេះចង់រួមចំណែកក្នុងការវិភាគលើផលប្រយោជន៍ និងផលវិបាកនៃការបណ្តេញចេញ ក្នុងន័យដើម្បីសម្របសម្រួលការអភិវឌ្ឍក្នុងរាជធានីភ្នំពេញ។ អង្គការសមាគមធាងត្នោតបានពិនិត្យឡើងវិញលើទីតាំងបណ្តេញចេញទាំង៧៧ទីតាំង ដែលខ្លួនបានកំណត់កាលពីឆ្នាំ២០១១ ដើម្បីមើលថាតើមានការអភិវឌ្ឍអ្វីខ្លះបានកើតឡើងនៅលើទីតាំងទាំងនោះ។ តាមការ

---

[10] Senghor, S. (2015). Driving Forces of Future Cambodia's Economic Growth. Development Research Forum Synthesis Report. No. 2, July 2015. Retrieved from: http://www.cdri.org.kh/webdata/policybrief/drf/SynthesisReport2-2015.pdf
[11] World Bank Group. (2015). Cambodia Economic Update. October 2015. Retrieved from: http://www.eurocham-cambodia.org/uploads/a7b60-wb-cambodia-economic-update-oct-2015.pdf
[12] Baliga A., and Sokheng, V. (2016, April 18). ELCs earn just $5M for gov't. Phnom Penh Post. Retrieved from: http://www.phnompenhpost.com/national/elcs-earn-just-5m-govt

ស្រាវជ្រាវរបស់យើងបានរកឃើញថា មានតែ៣៥%នៃទីតាំងទាំង៧៧មានការអភិវឌ្ឍពេញលេញ ៤០% មានការអភិវឌ្ឍខ្លះៗ ចំណែក២៥%ទៀតមិនមានការអភិវឌ្ឍទាល់តែសោះ។ ការសិក្សាស្រាវជ្រាវនេះក៏បានរកឃើញដែរថា នៅទីតាំងទាំងនោះមានការអភិវឌ្ឍចំនួន៣ប្រភេទ ដូចជា ការសាងសង់អាគារសម្រាប់ស្នាក់នៅ ការអភិវឌ្ឍសម្រាប់ពាណិជ្ជកម្ម ឬអាជីវកម្ម និងការកែលំអរផ្លូវ ឬពង្រីកផ្លូវ។ នៅពេលដែលសម្ភាស ប្រជាសហគមន៍ដែលកំពុងរស់នៅលើតំបន់បណ្តេញចេញ ឬក្បែរតំបន់បណ្តេញចេញ ៩១%បានបញ្ជាក់ថា ពួកគេមិនប្រាកដថាតើអ្វីដែលកំពុងអភិវឌ្ឍនៅទីនោះគឺស្របទៅនឹងផែនការដែលបានស្នើរសុំឬយ៉ាងណានោះទេ ហើយ៩៧% បាននិយាយថាពួកគេមិនដឹងថាតើមានអ្វីកំពុងកើតឡើងនៅក្នុងទីតាំងទាំងនោះឱ្យប្រាកដនោះទេ។ លើសពីនេះទៅទៀត អង្គការសមាគមធាងត្នោតបានពិនិត្យទៅលើផលប៉ះពាល់ពីការបណ្តេញចេញ ឬពីការអភិវឌ្ឍ ដែលកើតមានមកលើប្រជាសហគមន៍ក្រីក្រដែលកំពុងរស់នៅលើទីតាំងបណ្តេញចេញ ឬក្បែរទីតាំងបណ្តេញចេញ។ តាមការស្ទង់មតិរកឃើញថា ជាទូទៅជីវភាព និងស្ថានភាពរស់នៅរបស់ពួកគេកាន់តែពិបាកជាងមុន ប៉ុន្តែសេវាសាធារណៈមានភាពប្រសើឡើង ចំណែកឯការប្រាស្រ័យទាក់ទងនៅក្នុងសហគមន៍នៅដដែល។

រូបភាពទី១៖ ទីតាំងបណ្តេញចេញក្នុងរាជធានីភ្នំពេញ



## ១.២. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងដើម្បីៈ

- សិក្សាការអភិវឌ្ឍដែលកើតឡើងនៅតំបន់បណ្តេញចេញទាំង៧៧ទីតាំង ដែលបានរកឃើញដោយអង្គការសមាគធាងត្នោតឆ្នាំ២០១១ ក្នុងន័យដើម្បីកំណត់ថាតើពាក្យសន្យាត្រូវបានគោរព;
- វិភាគថាតើសាលារាជធានីភ្នំពេញ ឬក្រុមហ៊ុនអភិវឌ្ឍន៍បានអភិវឌ្ឍអ្វីខ្លះនៅលើទីតាំងបណ្តេញចេញ ដូចជាការគ្រោងទុកពីមុនដែរឬទេ;
- វាយតម្លៃស្ថានភាពរស់នៅរបស់សហគមន៍ដែលមានលំនៅដ្ឋាននៅលើទីតាំង ឬក្បែរទីតាំងបណ្តេញចេញ;
- ផ្តល់នូវអនុសាសន៍ដល់អ្នកពាក់ព័ន្ធទាំងឡាយ (ដូចជា រាជរដ្ឋាភិបាលកម្ពុជា ម្ចាស់ជំនួយ ក្រុមហ៊ុនឯកជន សហគមន៍) អំពីផែនការអភិវឌ្ឍន៍ទីក្រុងនាពេលអនាគតដោយផ្អែកលើការរកឃើញពីការសិក្សាស្រាវជ្រាវនេះ។

## ១.៣. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ទោះបីជាការសិក្សាស្រាវជ្រាវនេះ បង្ហាញពីផលវិបាកនៃការបណ្តេញចេញដោយបង្ខំទៅលើសហគមន៍ក្រីក្រក៏ដោយ ក៏យើងមើលទៅផលប្រយោជន៍រយៈពេលខ្លី និងរយៈពេលវែង នៃការអភិវឌ្ឍផងដែរ។ ការអភិវឌ្ឍទីក្រុងគឺជាកត្តាដែលជំរុញឱ្យមានការបណ្តេញចេញនៅក្នុងទីក្រុងភ្នំពេញ ហើយដោយហេតុផលនេះហើយ ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់សម្រាប់ការវិភាគលើផលប្រយោជន៍ និងផលវិបាកនៃការអភិវឌ្ឍទីក្រុងនាពេលអនាគត។ ការសិក្សាស្រាវជ្រាវនេះ ក៏មានសារៈសំខាន់ក្នុងការកំណត់ថា តើការបណ្តេញចេញដោយបង្ខំគួរតែកើតមានទៀត ឬយ៉ាងណា ដោយសារភាពរីកចម្រើននៃការអភិវឌ្ឍនៅលើទីតាំងទាំង៧៧ មិនមានអ្វីប្រែប្រួលច្រើន ហើយដែលជាប្រធានបទសម្រាប់ការសិក្សារស្រាវជ្រាវនេះ។

ជាទូទៅ ការសិក្សាស្រាវជ្រាវនេះគឺជាប្រភពព័ត៌មាន និងចំណេះដឹងនៃផលប៉ះពាល់ជាអវិជ្ជមានដោយការអភិវឌ្ឍ (ដោយផ្ទាល់ ឬដោយប្រយោល) ឬសម្រាប់គាំទ្រសហគមន៍នានា (ដូចជាអង្គការមិនមែនរដ្ឋាភិបាល អង្គការមនុស្សធម៌ ក្រុមសិទ្ធិមនុស្ស)។ ជាពិសេស ការសិក្សាស្រាវជ្រាវនេះ ព្រមទាំងអនុសាសន៍នៃការសិក្សាស្រាវជ្រាវនេះគឺមតិយោបល់ដែលផ្តល់ទៅដល់អាជ្ញាធរ ក្រុមហ៊ុនអភិវឌ្ឍន៍ (ទាំងសាធារណៈ និងឯកជន) និងសហគមន៍អន្តរជាតិ សម្រាប់ធ្វើការពិចារណានៅពេលធ្វើផែនការ ឬគាំទ្រការអភិវឌ្ឍនាពេលអនាគត ឬអនុវត្តច្បាប់នានាដើម្បីការពារអ្នករងគ្រោះដោយការអភិវឌ្ឍ។

ជាចុងក្រោយ សមត្ថភាពក្នុងការឃ្លាំមើលលើការអភិវឌ្ឍក្រុង និងវាយតម្លៃផលប៉ះពាល់នៃការអភិវឌ្ឍមកលើប្រជាពលរដ្ឋ ជាពិសេសប្រជាសហគមន៍ក្រីក្រ នឹងក្លាយទៅជាប្រភពព័ត៌មានយោងដ៏ល្អមួយសម្រាប់ការសិក្សាស្រាវជ្រាវនាពេលអនាគតទាក់ទងនឹងប្រធានបទនេះ។

# ជំពូក ២ វិធីសាស្ត្រនៃការស្រាវជ្រាវ

## ២.១. លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស

ការសិក្សាស្រាវជ្រាវមើលលក្ខខណ្ឌចំនួនពីរ (ការចុះអង្កេតទីតាំងនៃការបណ្តេញដោយផ្ទាល់ និងការសម្ភាសអ្នករស់នៅលើទីតាំងលើ ឬក្បែរទីតាំងបណ្តេញចេញ)

- ទីតាំងបណ្តេញចេញគឺត្រូវបានកំណត់ដោយយោងទៅតាមផែនទីឆ្នាំ២០១១ "ទីតាំងបណ្តេញចេញ"។ ផែនទីនេះស្របទៅនឹងផែនទីនៃការបណ្តេញចេញដោយបង្ខំ៤ផ្សេងទៀត ដើម្បីកំណត់ទីតាំងភូមិសាស្ត្រ[13]។
- ប្រជាសហគមន៍ដែលរស់នៅលើទីតាំង និងក្បែរទីតាំងបណ្តេញចេញត្រូវបានជ្រើសរើសសម្រាប់ធ្វើជាសំណាកនៃការស្រាវជ្រាវតាមគោលការណ៍ស្ម័គ្រចិត្ត។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះត្រូវបានសម្ភាសទាក់ទងទៅនឹងការយល់ដឹងរបស់ពួកគេអំពីផែនការអភិវឌ្ឍន៍ក្នុងពេលបច្ចុប្បន្ននៅក្នុងទីតាំងនានា និងផលប៉ះពាល់នៃការអភិវឌ្ឍ និង/ឬ ការបណ្តេញចេញមកលើជីវភាពរស់នៅរបស់ពួកគេ។

## ២.២. វិធីសាស្ត្រនៃការប្រមូលទិន្នន័យ

### ២.២.១. ប្រភពទិន្នន័យចំបង

<u>ក. ការសង្កេតទីតាំង</u>

ការសង្កេតត្រូវបានធ្វើឡើងដើម្បីមើលពីស្ថានភាពអភិវឌ្ឍន៍នានា ក្នុងពេលបច្ចុប្បន្ននៅក្នុងទីតាំងបណ្តេញចេញនីមួយៗ។ ការសង្កេតត្រូវបានធ្វើឡើងដោយផ្អែកលើការចូលទៅដល់ទីតាំង ការអភិវឌ្ឍបន្ថែម និងការប្រើប្រាស់ទីតាំង។ ជាពិសេស ការសង្កេតនេះ ជួយកំណត់ដំណាក់កាល និងការរីកចម្រើននៃការអភិវឌ្ឍនៅក្នុងទីតាំងបណ្តេញចេញនីមួយ។ ក្រុមការងារស្រាវជ្រាវក្នុងការចុះសង្កេតមានដូចជា មន្ត្រីស្រាវជ្រាវមួយរូប និងអ្នកហាត់ការផ្នែកស្រាវជ្រាវពីររូប ដែលចុះទៅទីតាំងផ្ទាល់ដើម្បីសង្កេត និងថតរូបទីតាំងទាំងនោះ។ ក្រុមការងារបានចំណាយពេលពី១៥ ទៅ២០នាទី សម្រាប់ធ្វើការសង្កេតនៅក្នុងទីតាំងនីមួយៗ។

<u>ខ. ការស្ទង់មតិសហគមន៍</u>

ការស្ទង់មតិសហគមន៍ត្រូវបានធ្វើឡើងបន្ថែមទៅលើការសង្កេតទីតាំង ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធនានាពីអ្នកដែលទទួលរងផលប៉ះពាល់ដោយការបណ្តេញចេញ ឬការអភិវឌ្ឍ។

[13] Refer to appendix 1 for the map names and N/A sites.

ការស្ទង់មតិនេះត្រូវបានធ្វើឡើងក្នុងពេលដំណាលគ្នានៃការចុះសង្កេតទីតាំង ហើយត្រូវបានធ្វើបន្ទាប់ពីបញ្ចប់ការសង្កេតទីតាំង ដោយអ្នកស្រាវជ្រាវរបស់យើង។ ការស្ទង់មតិមួយត្រូវបានធ្វើឡើងក្នុងទីតាំងនីមួយៗជាមួយនឹងសមាជិកសហគមន៍ម្នាក់។ អ្នកប្រមូលទិន្នន័យស្វែងរកអ្នកត្រូវសម្ភាសដោយធ្វើដំណើរពីផ្ទះមួយទៅផ្ទះមួយ ឬជុំវិញទីតាំងបណ្តេញចេញ ដែលជាទីតាំងមានប្រជាសហគមន៍ក្រក្រីធ្លាប់រស់នៅ។ ក្រុមការងារស្រាវជ្រាវបានសម្ភាសមនុស្ស៥៦នាក់ នៅក្នុង៥៦ទីតាំង។ ទីតាំងចំនួន៣១ ទៀតមិនមានប្រជាសហគមន៍ក្រក្រីរស់នៅទីនោះ ឬក្បែរទីតាំងទាំងនោះទេ ឬអ្នករស់នៅទីនោះមិនចង់ចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ។ ការបណ្តេញចេញដោយបង្ខំគឺជាបញ្ហាដែលកើតឡើងជាបន្តបន្ទាប់នៅក្នុងប្រទេសកម្ពុជា ហើយសកម្មជនដីធ្លី បុគ្គលិករបស់អង្គការសមាគមធាងត្នោត ក៏ដូចជាបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលដទៃទៀតត្រូវបានទទួលរងការគំរាមកំហែង បំភិតបំភ័យ និងចាប់ដាក់ពន្ធនាគារដោយសារតែធ្វើការងារលើបញ្ហានេះ។ ដូចនេះហើយ ប្រជាសហគមន៍មួយចំនួនមិនហ៊ានចូលរួមក្នុងកិច្ចសម្ភាសរបស់យើងទេដោយសារពួកគេមានការភ័យខ្លាចថាពួកគេនឹងទទួលរងការគំរាមកំហែង ការសម្លុត និងអំពើហិង្សានានា ប្រសិនបើគេហ៊ានផ្តល់បទសម្ភាសជាមួយអ្នកស្រាវជ្រាវ មកពីអង្គការនានាទាក់ទងទៅនឹងការបណ្តេញចេញដោយបង្ខំ។ លើសពីនេះទៅទៀត មនុស្សភាគច្រើនដែលមករស់នៅក្រោយការបណ្តេញចេញ មិនបានដឹងអំពីបញ្ហានេះឡើយ ដូចនេះហើយពួកគេមិនបានផ្តល់ចម្លើយគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវនេះទេ។ ក្រុមអ្នកស្រាវជ្រាវបានចំណាយពេលជាមធ្យមពី១៥ ទៅ២០នាទី ក្នុងកិច្ចសម្ភាសនីមួយៗ។

<u>គ. កិច្ចសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ</u>

កិច្ចសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗគឺជាឧបករណ៍សង្គមដ៏ចំបងមួយ ដែលត្រូវបានប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យបែបគុណភាព និងជួយឱ្យអ្នកស្រាវជ្រាវទទួលបានព័ត៌មានបន្ថែមទាក់ទងទៅនឹងគោលនយោបាយ និងផែនការអភិវឌ្ឍន៍នានាពេលបច្ចុប្បន្ន។ នៅក្នុងការសិក្សាស្រាវជ្រាវនេះ កិច្ចសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗត្រូវបានធ្វើឡើងជាមួយនឹងអ្នកពាក់ព័ន្ធមួយចំនួនដូចជា៖

i. ប្រជាសហគមន៍ក្រីក្រដែលទទួលរងផលប៉ះពាល់ដោយការបណ្តេញដោយបង្ខំ (តាមរយៈកិច្ចពិភាក្សាក្រុម);
ii. អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង (តាមរយៈការសម្ភាស);
iii. អង្គការសម្ព័ន្ធខ្មែរ ជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (តាមរយៈការសម្ភាស).

កិច្ចពិភាក្សាក្រុមត្រូវបានដឹកនាំ និងសម្របសម្រួលដោយអង្គការសមាគមធាងត្នោតដើម្បីទទួលបានព័ត៌មានបែបគុណភាពទាក់ទងទៅនឹងបទពិសោធផ្ទាល់ខ្លួនរបស់ពួកគេអំពីផលប៉ះពាល់នៃការបណ្តេញចេញ និងការអភិវឌ្ឍ មកលើជីវិត និងស្ថានភាពរស់នៅរបស់ពួកគេ ហើយនិងដើម្បី

ស្វែងយល់ពីការយល់ឃើញរបស់ពួកគេពីការអភិវឌ្ឍក្នុងសហគមន៍ក្រីក្រ[14]។ អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមស្នូលនេះមានចំនួន៧នាក់ ដែលតំណាងឱ្យសហគមន៍បណ្តេញចេញចំនួន៦ផ្សេងទៀតដូចជា សហគមន៍ជ្រោយចង្វារ សហគមន៍បុរីកីឡា សហគមន៍ភូមិ២៣ សហគមន៍ទួលសង្កែ សហគមន៍ស្ទឹងមានជ័យ និងសហគមន៍បឹងកក់[15]។ សហគមន៍មួយមានតំណាងសហគមន៍ម្នាក់ លើកលែងតែសហគមន៍បឹងកក់ ដែលមានអ្នកតំណាងពីរនាក់បានចូលរួម។ កិច្ចពិភាក្សាក្រុមបានចំណាយពេល២ម៉ោង និងប្រើប្រាស់សំណួរពាក់កណ្តាលផ្លូវការ និងសម្របសម្រួលដោយបុគ្គលិករបស់អង្គការសមាគមធាងត្នោត។

កិច្ចសម្ភាសពាក់កណ្តាលផ្លូវការ ត្រូវបានធ្វើឡើងជាមួយបុគ្គលិករបស់អង្គការចំនួនពីរដែលបានធ្វើការដោយផ្ទាល់ជាមួយនឹងសហគមន៍ក្រីក្រក្នុងទីក្រុង ដែលរងគ្រោះដោយការបណ្តេញចេញដោយបង្ខំ និងការអភិវឌ្ឍ។ មន្ត្រីស្រាវជ្រាវរបស់អង្គការសមាគមធាងត្នោតបានសម្ភាសអ្នកគ្រប់គ្រងកម្មវិធីរបស់អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង និងអ្នកគ្រប់គ្រងនៃការិយាល័យឃ្លាំមើល និងការពាររបស់អង្គការលីកាដូ[16]។ កិច្ចសម្ភាសនីមួយៗបានចំណាយពេលប្រហែល១ម៉ោង។

### ២.២.២. ទិន្នន័យបន្ទាប់បន្សំ

ទិន្នន័យដែលបានប្រើប្រាស់ក្នុងរបាយការណ៍នេះគឺមានប្រភពផ្សេងៗគ្នា ដូចជា របាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល របាយការណ៍ដែលចេញផ្សាយដោយរាជរដ្ឋាភិបាល របាយការណ៍ស្រាវជ្រាវរបស់បញ្ញវ័ន្តនានា សារព័ត៌មាន និងអត្ថបទបោះពុម្ពផ្សាយជាច្រើនទៀត។

## ២.៣. វិសាលភាព និងដែនកំណត់

ក្នុងពេលសរសេររបាយការណ៍ អង្គការសមាគមធាងត្នោតបានជួបឧបសគ្គជាច្រើន ក្នុងការប្រមូលព័ត៌មាន និងទិន្នន័យពីស្ថាប័ននានា រួមទាំងអាជ្ញាធរមូលដ្ឋាន និងស្ថាប័នរដ្ឋាភិបាល។

ចំណុចសំខាន់ដូចដែលបានបញ្ជាក់នៅក្នុងគោលបំណង គឺអង្គការសមាគមធាងត្នោតមានគោលបំណងកំណត់ថាតើការសន្យានៃការអភិវឌ្ឍត្រូវបានគោរព ដោយផ្អែកលើផែនការអភិវឌ្ឍន៍នៅក្នុងទីតាំងបណ្តេញចេញទាំង៧៧ ដែរឬទេ។ ប៉ុន្តែ ការមិនទទួលបានផែនការអភិវឌ្ឍន៍ពីសាលារាជធានីភ្នំពេញ និងក្រុមហ៊ុនអភិវឌ្ឍន៍ វាធ្វើឱ្យមានការលំបាកក្នុងការប្រៀបធៀបឱ្យបានស៊ីជម្រៅរវាងផែនការអភិវឌ្ឍន៍ និងការអភិវឌ្ឍជាក់ស្តែង។ ឧទាហរណ៍ជាក់ស្តែងគឺលិខិតមួយច្បាប់ដែលបានដាក់ទៅសាលារាជធានីភ្នំពេញ[17] ដោយបានពន្យល់អំពីគោលបំណងនៃការសិក្សាស្រាវជ្រាវ និងមូលហេតុនៃផែនការអភិវឌ្ឍន៍។ ប៉ុន្តែ ការស្នើសុំនេះត្រូវបានបដិសេធដោយសាលារាជធានី

[14] Refer to Annex 3 for the full FGD checklist.
[15] Refer to Annex 3 for the full FGD checklist.
[16] Refer to Annex 4 for the full UPWD interview checklist, and Annex 5 for the full LICADHO interview checklist.
[17] Refer to appendix 2.

ភ្នំពេញ និងក្រសួងផែនការ ដោយក្រោមហេតុផលថាស្ថាប័នទាំងពីរមិនទទួលខុសត្រូវលើផែនការទាំងនេះឡើយ។

អង្គការសមាគមធាងត្នោតធ្លាប់ជួបបញ្ហាប្រឈមទាំងនេះពីមុនរួចមកហើយ នៅពេលដែលព្យាយាមធ្វើការជាមួយអាជ្ញាធររបស់រដ្ឋាភិបាលទាក់ទងទៅនឹងបញ្ហាដីធ្លី និងសិទ្ធិរបស់ប្រជាសហគមន៍ក្រីក្រនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ២០១១ រាជរដ្ឋាភិបាលកម្ពុជា បានផ្អាកការងារជាបណ្ដោះអាសន្នរបស់អង្គការសមាគមធាងត្នោត[18] រយៈពេល៥ខែ បន្ទាប់ពីអង្គការមួយនេះបានចេញផ្សាយរបាយការណ៍មួយស្ដីអំពី "ការសាងសង់ឡើងវិញនូវផ្លូវដែកក្នុងប្រទេសកម្ពុជា៖ ការប្រៀបធៀបទិន្នន័យដែលចុះសង្កេតផ្ទាល់"។ របាយការណ៍នេះលើកឡើងពីការផ្ដល់សំណងមិនសមរម្យដល់ប្រជាសហគមន៍ក្រីក្រ ដែលទទួលរងផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍ផ្លូវដែកនេះ។

បញ្ហាប្រឈមផ្សេងទៀតមានដូចជា ការកំណត់សហគមន៍នៃតំបន់បណ្ដេញចេញ ដើម្បីឱ្យពួកគាត់ចូលរួមក្នុងការស្រាវជ្រាវនេះ។ ទីតាំងមួយចំនួនមិនមានប្រជាសហគមន៍រស់នៅក្បែរ ដែលនាំឱ្យមានការកាត់បន្ថយចំនួនអ្នកចូលរួមក្នុងកិច្ចសម្ភាស។ លើសពីនេះទៅទៀត ទោះបីជានៅទីតាំងខ្លះមានប្រជាសហគមន៍រស់នៅក៏ដោយ ក៏ពួកគេមានភាពស្ទាក់ស្ទើរក្នុងការឆ្លើយសំណួរទាក់ទងទៅនឹងកម្មសិទ្ធិដីធ្លី និងស្ថានភាពរស់នៅ ដោយសារពួកគាត់មានការព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន និងបារម្ភថានឹងមិនទទួលបានសំណងដែលគេសន្យាថាផ្ដល់ឱ្យ។

ចុងក្រោយ ដោយសារកង្វះខាតនៃការចងក្រងឯកសារទាក់ទងទៅនឹងការតាំងទីលំនៅក្នុងទីក្រុង អ្នកស្រាវជ្រាវបានជួបផលលំបាកជាច្រើនក្នុងការកំណត់ព្រំប្រទល់ជាក់លាក់នៃទីតាំងជាច្រើន ដែលនេះធ្វើឱ្យយើងពឹងផ្អែកលើការប៉ាន់ស្មានច្រើន។ ទិន្នន័យបឋមរួមមានចំណុច ជីភីអេស (GPS) មិនមានព័ត៌មានទាក់ទងទៅនឹងទំហំ ឬព្រំប្រទល់នៃទីតាំងបណ្ដេញចេញ។ ការប៉ាន់ស្មានត្រូវបានធ្វើឡើងដោយផ្អែកទៅលើការប៉ានស្មានរបស់ប្រជាសហគមន៍ នៅពេលដែលសួរពួកគាត់អំពីព្រំប្រទល់របស់ទីតាំង។

[18] The Phnom Penh Post. (2011). STT blasts its suspension. Phnom Penh, Cambodia. Accessed on 3rd November 2016, available at: http://www.phnompenhpost.com/national/stt-blasts-its-suspension

# ជំពូកទី៣ ការរកឃើញ

## ៣.១. សេចក្តីសង្ខេបអំពីទីតាំងបណ្តេញចេញ

នៅក្នុងឆ្នាំ២០១៤ អង្គការសមាគមធាងត្នោតបានចេញផ្សាយរបាយការណ៍មួយថា ចាប់តាំងពីឆ្នាំ១៩៩០មក មានប្រជាពលរដ្ឋជាង ២៩៧០០នាក់ត្រូវបានបណ្តេញចេញពីលំនៅដ្ឋានរបស់ពួកគេ ក្រោមហេតុផលអភិវឌ្ឍន៍។ ក្រោយពីបានចុះទៅមើលទីតាំងដែលបានបណ្តេញទាំង៧៧ ក្នុងឆ្នាំ២០១៦ អង្គការសមាគមធាងត្នោតបានរកឃើញថា កម្រិតនៃការអភិវឌ្ឍនៅទីតាំងនីមួយៗមានភាពខុសគ្នាខ្លាំង។ ឧទាហរណ៍ មានតែ៣៥%នៃទីតាំងទាំងអស់ត្រូវបានអភិវឌ្ឍពេញលេញ ដូចជាសហគមន៍បុរីកីឡា ដែលត្រូវបានអភិវឌ្ឍបែបពាណិជ្ជកម្ម។ មានប្រជាពលរដ្ឋចំនួន ១៤២៦ នាក់រស់នៅក្នុងសហគមន៍នេះ ហើយត្រូវបានបណ្តេញដោយបង្ខំក្នុងឆ្នាំ២០០៥ដល់ឆ្នាំ២០០៩។ តំបន់ខ្លះដែលមានការអភិវឌ្ឍ ដូចជា កោះពេជ្រ ជាដើម មានការផ្លាស់ប្តូរច្រើន។ កោះពេជ្រគឺត្រូវបានពង្រីកដោយការចាក់ដីបំពេញ ហើយអ្នករស់នៅទីនោះភាគច្រើនគឺក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន (សូមអានករណីសិក្សាទី១ "កោះពេជ្រ")។ ប៉ុន្តែ ៦៥%នៃទីតាំងបណ្តេញចេញទាំងអស់ មានការអភិវឌ្ឍ តិចតួច ហើយទីតាំងខ្លះមិនមានការអភិវឌ្ឍតែម្តង (សូមអានផ្នែក ៣.២.១ ខាងក្រោម ដែលពិភាក្សាលំអិតអំពីការរកឃើញនេះ)។ ឧទាហរណ៍ ក្នុងឆ្នាំ២០០៦ ប្រជាសហគមន៍ជាង ១០០០ គ្រួសារត្រូវបានបណ្តេញចេញពីសហគមន៍សំបុកចាប[19] ហើយបន្ទាប់ពីការបណ្តេញចេញ ១០ឆ្នាំនេះគឺឃើញមានតែផ្សាររាត្រី និងតារាងបាល់ទាល់ប៉ុណ្ណោះនៅលើទីតាំងនោះ។ សហគមន៍បឹងកក់ដែលមានប្រជាពលរដ្ឋចំនួន ២៦៨៨ នាក់ត្រូវបានបណ្តេញចេញដោយបង្ខំ ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១១ គឺមានឃើញតែការចាក់ខ្សាច់បំពេញបឹង និងមិនការអភិវឌ្ឍជាដុំកំភួនឡើយ (សូមអានករណីសិក្សាទី២ "បឹងកក់")។ លើសពីនេះទៅទៀត នៅក្នុងទីតាំងមួយចំនួនដូចជា វត្តសារាវ័ន្ត (៥៧០គ្រួសារត្រូវបានបណ្តេញចេញក្នុងឆ្នាំ១៩៩០) និងប្លុកតានប៉ា (សូមអានករណីសិក្សាទី៣ "ប្លុកតានប៉ា") គឺមិនមានការអភិវឌ្ឍទាល់តែសោះបន្ទាប់ពីការបណ្តេញចេញ។ ទាំង៧៧ទីតាំង មានតែ ៤១% ត្រូវបានអភិវឌ្ឍដោយក្រុមហ៊ុនឯកជន, ២៦% ជាកម្មសិទ្ធិរបស់រដ្ឋាភិបាល និង៣២% មិនអាចកំណត់បានដោយសារតែមិនមានស្លាកសញ្ញា ឬព័ត៌មានបិទផ្សាយជាសាធារណៈ។

មានការបារម្ភមួយទាក់ទងទៅនឹងការបណ្តេញចេញដោយបង្ខំ គឺការមិនបានទទួលដំណឹងមុនការបណ្តេញ និងសំណងដែលគ្រួសារនីមួយៗនឹងទទួលបាន។ នៅក្នុង៤៥ ទីតាំង ទិន្នន័យបានបង្ហាញថា អ្នកដែលត្រូវបានគេបណ្តេញចេញ ទទួលបានការជូនដំណឹងខ្លះ (ជាទូទៅតាមរយៈ

[19] LICADHO. (2016). Statement: Forced Eviction of Sambok Chab Village. [online] Available at: http://www.licadho-cambodia.org/pressrelease.php?perm=118 [Accessed 10 Nov. 2016].

សាលារាជធានី ភ្នំពេញ និងអាជ្ញាធរមូលដ្ឋាន ដូចជាក្នុងករណីសហគមន៍សែនរីករាយ និងសហគមន៍បន្ទាយស្លឹក)[20]។

លើសពីនេះ គ្រួសារមួយចំនួនតូចប៉ុណ្ណោះដែលទទួលបានសំណងសមរម្យនៅពេលដែលមានករណីរបណ្តេញចេញពីលំនៅដ្ឋានកើតឡើង (១៥%នៃទីតាំងបានប្រាប់អង្គការសមាគមធាងត្នោតថា មានការផ្តល់សំណង ហើយ៨៤%មិនដឹងច្បាស់ថាទទួលបានសំណងចំនួនប៉ុន្មាន[21])។ នៅក្នុងករណីខ្លះ ការផ្តល់សំណងជាសាច់ប្រាក់ក្នុងចន្លោះពី២៥០ដុល្លារ ទៅ៨០០០ដុល្លារអាមេរិក[22]។ ករណីមួយផ្សេងទៀត ដូចជា ទីតាំងខាងកើតស្ពានជ្រោយចង្វារ ប្រជាពលរដ្ឋទទួលបានសំណងជាដីមួយប្លង់តូច (១០ គុណ ៣០ ម៉ែត្រ)។ ការផ្តល់សំណងកាន់តែមិនសមរម្យសម្រាប់អ្នកដែលមានឯកសារកាន់កាន់ដីធ្លី ដូចជា ក្នុងករណីសហគមន៍ទួលសង្កែអា ដែលប្រជាសហគមន៍ទទួលបានឯកសារកាន់កាប់ដីធ្លីពីសាលារាជធានីភ្នំពេញ ប៉ុន្តែពួកគេទទួលបានត្រឹមតែ៥០០ដុល្លាសហរដ្ឋអាមេរិកប៉ុណ្ណោះ នៅពេលដែលពួកគេត្រូវបានបណ្តេញចេញពីដីធ្លីរបស់ខ្លួន។

ក្នុងឆ្នាំ២០០១ ច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានធ្វើវិសោធនកម្ម[23]។ ការធ្វើវិសោធនកម្មនេះ អនុញ្ញាតិឱ្យបុគ្គលណាដែលរស់នៅលើដី (ដែលកាន់កាប់ដោយឯកជន) មានសិទ្ធិគ្រប់គ្រាន់ក្នុងការដាក់ពាក្យស្នើសុំកាន់កាប់អចលនទ្រព្យ ប្រសិនបើជននោះបានរស់នៅលើដីនោះយ៉ាងហោចណាស់៥ឆ្នាំ[24]។ ប៉ុន្តែ សិទ្ធិទទួលបាន និងការអនុវត្តជាក់ស្តែងគឺមិនដូចគ្នានោះទេ។ កង្វះខាតចំណេះដឹងទាក់ទងទៅនឹងនីតិវិធីនានាដើម្បីទទួលបានប្លង់កាន់កាប់ដីធ្លី និងអំពើពុករលួយជាប្រព័ន្ធនៅថ្នាក់មូលដ្ឋាន[25] បានធ្វើឱ្យអ្នកដែលត្រូវបានគេបណ្តេញចេញមិនអាចទទួលបាននូវឯកសារទាំងនេះឡើយ។

---

[20] Sahmakum Teang Tnaut, (2014). Phnom Penh's History of Displacement – Evicted Communities From 1990 to 2014. Facts and Figures #23. [online] Phnom Penh, pp.1-9. Available at: http://teangtnaut.org/wp-content/uploads/2014/12/FactFigures23_Evicted-Communities-PP-1990-2014_VsFinal.pdf [Accessed 28 Oct. 2016].

[21] Ibid.

[22] Communities Survey Data: see appendix 4

[23] Council for the Development of Cambodia, (2001). Updated Land Law. Phnom Penh.

[24] Sahmakum Teang Tnaut, (2013). Policy for the Poor? Phnom Penh, Tenure Security, and Circular 03. The Urban Initiative. [online] p.34. Available at: http://teangtnaut.org/wp-content/uploads/2013/08/The-UI_Policy-for-the-Poor_2013.pdf [Accessed 31 Oct. 2016].

[25] Bristol, G. (2016). Cambodia: the struggle for tenure. Case study prepared for Enhancing Urban Safety and Security: Global Report on Human Settlements 2007. [online] p.11. Available at: http://unhabitat.org/wpcontent/uploads/2008/07/GRHS.2007.CaseStudy.Tenure.Cambodia.pdf [Accessed 27 Oct. 2016].

## ៣.១.១. ករណីសិក្សា

| *ករណីសិក្សាទី១៖ កោះពេជ្រ* | |
|---|---|
| *កម្រិតនៃការអភិវឌ្ឍ៖ បញ្ចប់*<br>*ទីតាំង៖ កោះ*<br>*មូលហេតុបណ្តេញចេញ៖ ការអភិវឌ្ឍបរទេស* | *ចំនួនគ្រួសារ៖ ៣០០*<br>*ស្ថានភាព៖ ត្រូវបានគេបណ្តេញចេញ*<br>*តំបន់តាំងទីលំនៅថ្មី៖ ដំណាក់ត្រយឹង ឬអង្គស្នួល (៣០ គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ)* |

*<u>ទិដ្ឋភាពទូទៅ៖</u>*

*ជាដីមានជីវជាតិ ងាយស្រួលប្រើប្រាស់ទឹក និងជិតផ្សារ កោះពេជ្រ បានទាក់ទាញមនុស្សប្រហែល៣០០ គ្រួសារមករស់នៅទីនេះ។ ប៉ុន្តែ តម្លៃដីនៅទីនោះត្រូវបានគេប៉ាន់ស្មានថាមានតម្លៃ ប្រហែល១៧លានដុល្លាអាមេរិក[26] ហើយវាបានទាក់ទាញឱ្យមានចំណាប់អារម្មណ៍ក្នុងការអភិវឌ្ឍន៍ក្នុងតំបន់នោះ ហើយនៅក្នុងឆ្នាំ២០០៥ ប្រជាសហគមន៍ជិតពាក់កណ្តាលត្រូវបានបណ្តេញចេញ។ ប្រជាសហគមន៍ដែលនៅសល់ត្រូវបានដោះស្រាយទៅតាមវិធីផ្សេងៗរៀងៗខ្លួន។ កោះនេះនឹងក្លាយទៅជាតំបន់កំសាន្ត និងទីកន្លែងរស់នៅ ក្រោមការអភិវឌ្ឍរបស់ក្រុមហ៊ុនអូស៊ីអាយស៊ី ឬសេវិន អេន ជី (OCIC/7NG)។*

*<u>សម្លេងរបស់សហគមន៍៖</u>*

*ក្រោយពីបានឮពាក្យចចាមអារាមនៃការបណ្តេញចេញពីសំណាក់ក្រុមហ៊ុន សេវិនអេនជី នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៤ ប្រជាសហគមន៍បានទទួលការជូនដំណឹងរបស់ក្រុមហ៊ុនទាក់ទងទៅនឹងការបណ្តេញចេញ ដោយទុកពេលឱ្យពួកគេចំនួន១ខែដើម្បីចាកចេញពីលំនៅដ្ឋានរបស់ពួកគេ។ ដោយយល់ថាដី និងលំនៅដ្ឋានរបស់ពួកគេនឹងត្រូវបានគេរំលោភយក ប្រជាសហគមន៍ដែលពាក់ព័ន្ធបានព្យាយាមរកដំណោះស្រាយនានាដែលពួកគេអាចទទួលយកបាន បើទោះបីដឹងថាសំណងវាមិនសមរម្យ និងស្របទៅតាមតម្លៃទីផ្សារក៏ដោយ[27]។*

*សំណង់នៅក្នុងកោះពេជ្រ*



*សំណង់ដែលបានសង់រួចរាល់ក្នុងកោះពេជ្រ*




*ប្រភព៖ ចិន វុដស៍ ឆ្នាំ២០១១*

[26] Rith, S. and Cochrane, L. (2005). Koh Pich: island in a stream of greed. The Phnom Penh Post. [online] Available at: http://www.phnompenhpost.com/national/koh-pich-island-stream-greed [Accessed 31 Oct. 2016].
[27] *Ibid*

## ករណីសិក្សាទី២៖ សហគមន៍បឹងកក់

| | |
|---|---|
| កម្រិតនៃការអភិវឌ្ឍ៖ អភិវឌ្ឍន៍ខ្លះៗ<br>ទីតាំង៖ បឹង<br>មូលហេតុនៃការបណ្តេញចេញ៖ ការអភិវឌ្ឍ | ចំនួនគ្រួសារ៖ ២៦៨៨<br>ស្ថានភាព៖ ត្រូវបានបណ្តេញចេញ<br>តំបន់តាំងទីលំនៅថ្មី៖ ច្រើនទីតាំង |

<u>ទិដ្ឋភាពទូទៅ៖</u>

បឹងកក់មានសហគមន៍ចំនួន៩ ដែលស្ថិតនៅជុំវិញបឹងកក់។ មានគ្រួសារជាច្រើនបានមករស់នៅទីនេះអស់ជាច្រើនទសវត្សមកហើយ។ ការអភិវឌ្ឍបានបណ្តាលឱ្យមានការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋានជាច្រើនគ្រួសារ។ ក្នុងឆ្នាំ២០០៧ រាជរដ្ឋាភិបាល និងក្រុមហ៊ុនស៊ូកាគូ បានចុះហត្ថលេខាជួលដី ១៣៣ ហិចតា នៅតំបន់បឹងកក់រយៈពេល៩៩ឆ្នាំ[28]។ ដោយការចាក់ខ្សាច់បំពេញ តំបន់នេះនឹងក្លាយទៅជា "ទីក្រុងអេកូ" ដែលរួមមានលំនៅដ្ឋានប្រណីត និងមជ្ឈមណ្ឌលពាណិជ្ជកម្ម ចំណែកតំបន់មួយទៀត (ភូមិ២) ត្រូវបានអភិវឌ្ឍទៅជាផ្លូវ។ ប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍បី ក្នុងចំណោមសហគមន៍ទាំង៩ បានផ្លាស់ប្តូរទីលំនៅ ក្រោយពីការបណ្តេញចេញ ចំណែកសហគមន៍ពីរទៀតមិនបានផ្លាស់ទីលំនៅឡើយ។ ការតាំងទីលំនៅថ្មីរបស់សហគមន៍៤ មិនទាន់ដឹងនៅឡើយ។ ការបណ្តេញចេញដោយបង្ខំ បណ្តាលឱ្យស្ត្រីបឹងកក់៤នាក់ត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារកាលពីខែកញ្ញា ឆ្នាំ២០១៦។ ពួកគេត្រូវបានដាក់ក្នុងពន្ធនាគារដោយសារតែពួកគេប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ។

<u>សម្លេងរបស់សហគមន៍៖</u>

នៅក្នុងកិច្ចពិភាក្សាក្រុមស្នូលដែលរៀបចំដោយអង្គការសមាគមផាងត្នោត គ្រួសារដែលទទួលរងផលប៉ះពាល់ដោយសារផែនការអភិវឌ្ឍន៍ បានប្រាប់ថា ជីវិតរបស់ពួកគេកាន់តែលំបាកជាងមុនក្រោយពីការបណ្តេញចេញ។ អ្នកចូលរួមម្នាក់បានលើកឡើងថា "វាលំបាកសម្រាប់ពួកយើងរស់ណាស់..ដោយសារតែមិនមានអគ្គីសនី ទឹកស្អាតប្រើប្រាស់ និងមណ្ឌលសុខភាព"។ ពួកគេបន្ថែមទៀតថា សមាជិកសហគមន៍មួយចំនួនបានបាត់បង់ការងារ ហើយអ្នកខ្លះទៀតក្លាយទៅជាអ្នកសុំទាន។

បឹកកក់ក្រោយការបណ្តេញចេញ បានចាក់បំពេញដោយខ្សាច់



បឹងកក់ក្រោយការបណ្តេញចេញ



ប្រភព៖ បិន វុដស៍ ឆ្នាំ២០១១

[28] Titthara, M. (2010). Boeung Kak villagers call on PM to intervene in land case. The Phnom Penh Post. [online] Available at: http://www.phnompenhpost.com/national/boeung-kak-villagers-call-pm-intervene-land-case [Accessed 31 Oct. 2016].

## ករណីសិក្សាទី៣៖ ប្លុកតានប៉ា

| | |
|---|---|
| កម្រិតនៃការអភិវឌ្ឍ៖ មិនមានការអភិវឌ្ឍន៍<br>ទីតាំង៖ ដំបូលអាគារ<br>មូលហេតុនៃការបណ្តេញចេញ៖ អាគារចាស់ ឬអគ្គីភ័យ | ចំនួនគ្រួសារ៖ ១៧<br>ស្ថានភាព៖ ត្រូវបានបណ្តេញចេញ<br>តំបន់តាំងទីលំនៅថ្មី៖ ក្រាំងអង្គ្រង២ |

*ទិដ្ឋភាពទូទៅ៖*

ប្រជាពលរដ្ឋនៅប្លុកតានប៉ាបានមកតាំងទីលំនៅ ក្រោយពីការដួលរលំរបបប៉ុលពតនៅឆ្នាំ១៩៧៩ ប៉ុន្តែដោយសារតែសំណង់អាគារមានភាពទ្រុតទ្រោម ហើយក្នុងឆ្នាំ២០០២[29] មានអគ្គីភ័យឆេះដំបូលនៅសហគមន៍ផងនោះ ប្រជាសហគមន៍ភាគច្រើនបានផ្លាស់ទៅរស់នៅខាងក្រៅក្រុងចម្ងាយ១១គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ ចំណែកឯប្រជាសហគមន៍ផ្សេងទៀតនៅតែបន្តរស់នៅតំបន់ក្បែរនោះដដែល។ ចាប់តាំងពីពេលប្តូរទីតាំងមក ស្ថានភាពរស់នៅប្រជាពលរដ្ឋមានភាពប្រសើរឡើង ដោយសារកន្លែងរស់នៅរបស់ពួកគេមានលក្ខណៈធំទូលាយ។ ចំណែកឯអគ្គិសនីវិញក៏មានប្រើប្រាស់ល្អប្រសើជាងពេលមុនក្រោយពេលបានផ្លាស់ប្តូរមកទីតាំងថ្មី។ ទោះបីជាយ៉ាងណាក៏ដោយ នៅតែមានបញ្ហាដែលធ្វើឱ្យសហគមន៍កាន់តែលំបាកជាងពីមុនទៅទៀតនោះ គឺកុមារនៅក្នុងសហគមន៍មិនបានទៅសាលារៀន ឱកាសការងារជាច្រើនត្រូវបានបាត់បង់។បន្ថែមពីនេះ ការរកទិញសម្ភារៈប្រើប្រាស់ និងរបស់របរលក់ដូរកាន់តែលំបាកទៅៗ។

*សម្លេងរបស់សហគមន៍៖*

បន្ទាប់ពីមានអគ្គីភ័យនៅក្នុងសហគមន៍មក មេភូមិប្លុកតានប៉ាបានជូនដំណឹងដល់អង្គការសមាគមធាងត្នោតតាមទូរស័ព្ទថា ពុំមានសំណងផ្តល់ជូនប្រជាពលរដ្ឋឡើយ។ ប៉ុន្តែកន្លែងដែលប៉ះពាល់នោះ អាជ្ញាធរមូលដ្ឋាននឹងផ្តល់ដីជំនួសវិញនៅក្បែរទីនោះ ទោះបីជាព្រំប្រទល់ពិតប្រាកដនៃដីនេះពុំមានភាពច្បាស់លាស់សម្រាប់សហគមន៍ក៏ដោយ។ នៅពេលដែលគ្មានសំណងណាមួយត្រូវបានផ្តល់ឱ្យ ប្រជាសហគមន៍ទំនងជាបានលក់ដីនោះជាការដោះដូរនឹងថ្លៃសំណងដែលគិតជាសាច់ប្រាក់ប្រហែលជាមានតម្លៃពី ២០០០០ដុល្លារទៅ ៣០០០០ដុល្លារសហរដ្ឋអាមេរិក។

អគ្គីភ័យនៅប្លុកតានប៉ា



សកម្មភាពចាក់ទឹកពន្លត់អគ្គីភ័យ



ប្រភព៖ ចន វិញ ឆ្នាំ២០០២

[29] Sahmakum Teang Tnaut, (2014). Phnom Penh's History of Displacement – Evicted Communities From 1990 to 2014. Facts and Figures #23. [online] Phnom Penh, pp.1-9. Retrieved from: http://teangtnaut.org/wp-content/uploads/2014/12/FactFigures23_Evicted-Communities-PP-1990-2014_VsFinal.pdf

## ៣.២ លទ្ធផលរកឃើញ - តើជាសន្យាខ្យល់?

គោលបំណងនៃរបាយការណ៍នេះ គឺដើម្បីពិនិត្យទៅលើទំហំនៃការអភិវឌ្ឍ និងប្រភេទហេដ្ឋារចនាសម្ព័ន្ធដែលបានកើតមានឡើងនៅតំបន់បណ្តេញចេញទាំង៧៧ ទីតាំង រួមទាំងការសិក្សាទៅលើស្ថានភាពរស់នៅរបស់ប្រជាសហគមន៍ក្រីក្រនៅតំបន់បណ្តេញចេញទាំងនោះ (ឬអ្នកដែលមានលំនៅដ្ឋាននៅក្បែរនោះ)។ ដើម្បីធ្វើការកំណត់ ថាតើការសន្យាលើការអភិវឌ្ឍទាំងអស់នោះ (មានដូចនៅក្នុងគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា[30]) ត្រូវបានគោរពឬយ៉ាងណា។ ការស្ទង់មតិចំនួនពីរត្រូវបានធ្វើឡើងនៅតំបន់នីមួយៗដែលរួមមាន៖ ទី១ «ការស្ទង់មតិដោយសង្កេតទីតាំង» ដោយបានវាយតម្លៃទៅលើស្ថានភាពរបស់ទីតាំង កម្រិតនៃការអភិវឌ្ឍ និងប្រភេទនៃការអភិវឌ្ឍ និងការប្រើប្រាស់ទីតាំងបច្ចុប្បន្ន។ ទី២ គឺ «ការស្ទង់មតិសហគមន៍» ដែលបានធ្វើការសម្ភាសប្រជាសហគមន៍រស់នៅលើតំបន់បណ្តេញចេញ និងរស់នៅក្បែរទីនោះ ដើម្បីស្វែងយល់ពីប្រភពចំណូល សេដ្ឋកិច្ចសង្គម កម្រិតយល់ដឹងពីផែនការអភិវឌ្ឍន៍ និងផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេបន្ទាប់ពីការបណ្តេញចេញ និងការអភិវឌ្ឍ។

### ៣.២.១ លទ្ធផលរកឃើញពីការស្ទង់មតិដោយការសង្កេតទីតាំង

ការស្ទង់មតិដោយសង្កេតនៅទីតាំង ត្រូវបានធ្វើឡើងម្តងមួយៗនៅទីតាំងទាំង៧៧កន្លែង ដើម្បីពិនិត្យមើលថា តើមានការអភិវឌ្ឍអ្វីខ្លះបានកើតមានឡើងនៅតំបន់បណ្តេញចេញដោយបង្ខំទាំងនោះ ដែលបានរកឃើញដោយសមាគមធាងត្នោតនៅក្នុងឆ្នាំ២០១១[31]។ ១១%នៃតំបន់បណ្តេញចេញទាំងអស់បានជួបប្រទះផលលំបាក ដោយសារតែមានការហាមឃាត់មិនឱ្យចូលទៅដល់ទីតាំងនោះ មានន័យថាការសង្កេតអាចធ្វើឡើងបានតែនៅជុំវិញតំបន់បណ្តេញចេញនោះតែប៉ុណ្ណោះ។

#### <u>៣.២.១.១. ការសិក្សាលើការអភិវឌ្ឍ</u>

ការរកឃើញពីការស្ទង់មតិដោយសង្កេតទីតាំងបានបង្ហាញថា ការអភិវឌ្ឍបច្ចុប្បន្ននៅតំបន់បណ្តេញចេញទាំងអស់នោះគឺ៖ បានអភិវឌ្ឍពេញលេញមាន៣៥% អភិវឌ្ឍន៍ខ្លះៗមាន ៤០% និងពុំទាន់មានការអភិវឌ្ឍសោះមាន២៥%នៃតំបន់បណ្តេញចេញសរុបទាំងអស់[32]។ លទ្ធផលរកឃើញថា មានការអភិវឌ្ឍបីប្រភេទដែលមានការលូតលាស់ច្រើនជាងគេនៅតំបន់នោះគឺអាគារលំនៅដ្ឋាន ការអភិវឌ្ឍពាណិជ្ជកម្ម ឬអាជីវកម្ម និងការជួសជុលឬពង្រីកផ្លូវ។ លទ្ធផលរកឃើញបន្ថែមទៀតថា ៧៦% នៃការអភិវឌ្ឍអាគារលំនៅដ្ឋាន គឺជាផ្ទះល្វែងដែលមានតម្លៃថ្លៃ។ សម្រាប់ការអភិវឌ្ឍពាណិជ្ជកម្ម ឬអាជីវកម្ម ៣៥%គឺជាមជ្ឈមណ្ឌលពាណិជ្ជកម្ម។ នេះគឺជាហេតុផលមួយដែរ

---

[30] Royal Government of Cambodia. (2013). Rectangular Strategy Phase III. Phnom Penh, Cambodia, p.5. Accessed via: http://www.cambodiainvestment.gov.kh/content/uploads/2013/11/2013-Rectangular-Strategy-III-En8.pdf

[31] Location: Denied – Eviction sites in Phnom Penh' 2011, STT (refer to section 1: Introduction)

[32] Refer to appendix 3 for the full list of which sites fall under the different categories of development.

សម្រាប់ការអភិវឌ្ឍតែ២០%ដោយកន្លែងនៃតំបន់ពាណិជ្ជកម្ម។ បន្ថែមពីនេះគឺ ២០%គឺជាការអភិវឌ្ឍផ្លូវដែក និង២០%ទៀតគឺស្ពានបនាផ្លូវថ្នល់។ ក្រៅពីនេះ ការស្ទង់មតិបានរកឃើញទៀតថា សាលារាជធានីភ្នំពេញ គឺជាស្ថាប័នជាតិដែលបានប្រើប្រាស់ការអភិវឌ្ឍ៨៣% នៃទីតាំងអភិវឌ្ឍខ្លះៗ និង៨៥% ទៀតនៃទីតាំងមានការអភិវឌ្ឍពេញលេញ។ ក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវបានគេរកឃើញថាក៏បានប្រើប្រាស់៨៥%នៃគម្រោងអភិវឌ្ឍពេញលេញ។ សរុបសេចក្តីមក គឺពុំមានការបញ្ជាក់ពីហានីភ័យណាមួយត្រូវបានរកឃើញនៅទីតាំងអភិវឌ្ឍទាំងនោះ ក្រៅពីសញ្ញាមិនល្អក្នុងការគ្រប់គ្រងកាកសំណល់ (៣៣%នៃទីតាំងទាំងអស់) និងផ្លូវខូច (៣០%នៃទីតាំងទាំងអស់)

## ៣.២.១.២ ការប្រើប្រាស់ទីតាំងនាពេលបច្ចុប្បន្ន

ភោជនីយដ្ឋានក្នុងបុរីកម្មករ



សាលារៀនក្នុងសហគមន៍ថៅពញ្ញាហុក



ទីកន្លែងរៀបចំពិធីផ្សេងៗ ផ្លូវ ២០២ (៨៥)



វត្តសារ៉ាវ័ន្ត



តារាងទី១រៀបរាប់ចំនួនទីតាំងដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងផ្សេងៗគ្នា។ ១៣ទីតាំងនៃ៧៧ទីតាំងពុំទាន់ទទួលបានការអភិវឌ្ឍនៅឡើយ និង៦៤ទីតាំងត្រូវបានបញ្ចប់ការអភិវឌ្ឍ ឬបានសាងសង់ខ្លះៗ (ដូចបានរៀបរាប់នៅផ្នែក ៣.២.១.១ខាងលើ) ជាពិសេសសម្រាប់ពាណិជ្ជកម្ម ឬលំនៅដ្ឋាន។ ហើយចំនួនតួលេខខ្ពស់របស់លំនៅដ្ឋាន (៦៨%) និងការអភិវឌ្ឍពាណិជ្ជកម្ម (៦០%)

ដែលបាននិងកំពុងគ្រប់គ្រង និងដំណើរការ។ ក្នុងចំណោមទីតាំងទាំង៦៤ មានតែ៨ទីតាំងប៉ុណ្ណោះដែលការអភិវឌ្ឍបានធ្វើឡើងឆ្លើយតបទៅនឹងសុខុមាលភាព និងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់។ ឧទាហរណ៍ ៥ទីតាំងត្រូវបានអភិវឌ្ឍទៅជាសាលារៀន មន្ទីរពេទ្យកុមារចំនួន២ និងមន្ទីរពេទ្យ១កន្លែង។

ការបណ្តេញចេញដោយបង្ខំ ត្រូវបានធ្វើឡើងនៅក្នុងទីតាំងទាំងនោះអស់រយៈពេលជាង២ទសវត្សរ៍ចុងក្រោយនេះ ដោយឈរលើគោលការណ៍ ឬជ្រកក្រោមពាក្យថា "អភិវឌ្ឍន៍" និងដើម្បី "សោភ័ណ្ឌភាពទីក្រុង"[33]។ អំណះអំណាងនៅក្នុងតារាងខាងក្រោមនេះគឺជាប្រភេទនៃការអភិវឌ្ឍ និងកម្រិតអភិវឌ្ឍន៍។ *យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាជំហានទីបី* បានចាត់ទុកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងភាពស៊ីវីល័យជា «កត្តាសំខាន់ក្នុងការជួយដល់កំណើនសេដ្ឋកិច្ចពង្រីកប្រសិទ្ធភាពសេដ្ឋកិច្ច ក៏ដូចជាការពង្រឹងការប្រកួតប្រជែង និងលើកកម្ពស់ពហុចំណូលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ជាពិសេសគឺការកាត់បន្ថយភាពក្រីក្រ [sic][34]។» ទោះបីជាយ៉ាងណាក៏ដោយការព្រួយបារម្ភនៅតែបន្តលើកឡើងពីប្រជាសហាគមន៍ដែលត្រូវបានបណ្តេញចេញ សង្គមស៊ីវិល និងសហាគមអន្តរជាតិ ទាក់ទងទៅនឹងផលប៉ះពាល់សេដ្ឋកិច្ចសង្គម ជីវភាព ស្ថានភាពរស់នៅរបស់ប្រជាសហាគមន៍ពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធយ៉ាងរហ័សបែបនេះ។ ជាពិសេស ការ ខិតខំប្រឹងប្រែងដើម្បីការអភិវឌ្ឍ និងសោភ័ណភាពទីក្រុងគឺដើម្បីពង្រឹងការអភិវឌ្ឍពាណិជ្ជកម្ម និងបង្កើតឱកាសរបស់ពួកគេ។ មានករណីសហាគមន៍សំបុកចាបជាឧទាហរណ៍ ប្រជាពលរដ្ឋត្រូវបាន "បណ្តេញចេញដោយហិង្សា" បើទោះបីជាប្រជាពលរដ្ឋមានឯកសារចេញដោយអាជ្ញាធរមូលដ្ឋាន ទទួលស្គាល់ពីសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់ក៏ដោយ[35]។ សាលាខណ្ឌបានចេញលិខិតប្រកាសជាផ្លូវការថាអាជ្ញាធរត្រូវការដី "ដើម្បីកែលម្អរសោភ័ណភាពទីក្រុង និងសម្រាប់ការអភិវឌ្ឍ" ហើយប្រជាសហាគមន៍ត្រូវរើចេញទៅរស់នៅទីតាំងថ្មីនៅឯក្រៅក្រុង[36]។ បើទោះជានៅពេលថ្មីៗនេះ អ្នកជំនាញខាងឧស្សាហ៍កម្មបានចូលរួមវេទិកាអចលនវត្ថុនៅទីក្រុងភ្នំពេញបានប្រកាសពីការព្រួយបារម្ភរបស់ពួកគេ ទៅលើភាពខ្វះខាតផែនការអភិវឌ្ឍន៍ទីក្រុង និងលិខិតអនុញ្ញាតិចេញដោយរាជរដ្ឋាភិបាលឆាប់រហ័សពេក[37]។ ក្រុមអ្នកជំនាញអំពាវនាវឱ្យមានបទបញ្ញាតិរឹងមាំក្នុងការធ្វើផែនការអភិវឌ្ឍន៍ហេដ្ឋា

---

[33] Lindstrom, N. (2013). Policy for the Poor? Phnom Penh, Tenure Security, and Circular 03. Sahmakum Teang Tnaut. Phnom Penh, Cambodia, p. 10.

[34] Royal Government of Cambodia. (2013). Rectangular Strategy Phase III. Phnom Penh, Cambodia, p.5. Accessed via: http://www.cambodiainvestment.gov.kh/content/uploads/2013/11/2013-Rectangular-Strategy-III-En8.pdf

[35] Bristol, G. (2016). Cambodia: the struggle for tenure. Case study prepared for Enhancing Urban Safety and Security: Global Report on Human Settlements 2007. [online] p.11. Available at: http://unhabitat.org/wpcontent/uploads/2008/07/GRHS.2007.CaseStudy.Tenure.Cambodia.pdf [Accessed 27 Oct. 2016].

[36] *Ibid.*

[37] Phnom Penh Post. (2016). Property forum slams lack of urban planning. Phnom Penh, Cambodia. Accessed via: http://www.phnompenhpost.com/business/property-forum-slams-lack-urban-planning

រចនាសម្ព័ន្ធ ហើយពិនិត្យឱ្យបានច្បាស់លាស់លើក្រុមហ៊ុនអភិវឌ្ឍន៍ដើម្បីធានាឱ្យមានការអភិវឌ្ឍប្រកបដោយចិរភាព[38]។

| ការពណ៌នាទីតាំងកំពុងប្រើប្រាស់[39] | ចំនួនទីតាំង |
| --- | --- |
| មិនទាន់មានការអភិវឌ្ឍ | ១៣ |
| អាគារផ្ទះល្វែង + ផ្ទះជាន់ | ៩ |
| ផ្ទះ+ ផ្ទះលើផ្លូវរថភ្លើង | ៧ |
| ពាណិជ្ជកម្ម + ពាណិជ្ជកម្មខ្នាតតូច | ៥ |
| អាគារពាណិជ្ជកម្ម | ៤ |
| សាលារៀន និងផ្សារ + មន្ទីរពេទ្យ និងសាលារៀន | ៥ |
| រាជាយស្ម័យាន (រថភ្លើង) | ៣ |
| ចំណតរថយន្ត | ៣ |
| សាងសង់ផ្លូវ + ផ្លូវល្បឿនលឿន + ស្ពាន | ៤ |
| ផ្ទះល្វែង ភោជនីយដ្ឋាន សួនច្បារ + ភោជនីយដ្ឋាន | ៤ |
| មន្ទីរពេទ្យកុមារ | ២ |
| ការអភិវឌ្ឍលំនៅដ្ឋាន និងផ្សារ | ២ |
| របង | ២ |
| ចាក់ខ្សាច់បំពេញ | ១ |
| ផ្សារទំនើប + ផ្សារកណ្តាល | ២ |
| វិថី | ១ |
| ផ្ទះល្វែង និងអាគារពាណិជ្ជកម្ម | ១ |
| ធានាគារ និងផ្ទះល្វែង | ១ |
| ផ្ទះវីឡា និងផ្ទះល្វែង | ១ |
| ទីលានបាល់ទាត់ | ១ |
| ប្រព័ន្ធលូបង្ហូរទឹក | ១ |
| ផ្ទះល្វែង និងផ្ទះសំណាក់ | ១ |
| អគារក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា (CDC) | ១ |

38 *Ibid.*

39 For the purpose of this report, 'flats' refer to low budget flats; 'apartments' refer to up-market apartments such as condominiums; and 'villas' refer to a large, luxury style country houses.

| | |
|---|---|
| សួនច្បារ | ១ |
| កន្លែងលាងរថយន្ត | ១ |
| វត្តអារាម | ១ |
| សរុប | ៧៧ |

*តារាងទី១៖ ការពិពណ៌នាទីតាំងបានប្រើប្រាស់*

ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់បន្ថែមទៀតថា តើការអភិវឌ្ឍបានរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ដូចដែលមានចែងនៅក្នុង *"គោលនយោបាយចតុកោណ ដំណាក់កាលទី៣"* វា ទាមទាឱ្យមានការវិភាគឱ្យបានស៊ីជម្រៅ លើផលប៉ះពាល់នៃការអភិវឌ្ឍមកលើស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាសហាគមន៍ក្រីក្រក្នុងទីក្រុង។ នៅក្នុងផ្នែក ៣.២.២ ខាងក្រោម បង្ហាញពីការរកឃើញលទ្ធផលនៃ "ការស្ទង់មតិសហាគមន៍" ដែលបានសិក្សាទៅលើស្ថានភាពរស់នៅរបស់ប្រជា ពលរដ្ឋ ដែលកំពុងរស់នៅក្នុងតំបន់នោះ ឬនៅក្បែរតំបន់នោះក្រោយពីការបណ្តេញចេញ។

## ៣.២.២.ការរកឃើញក្នុងការស្ទង់មតិសហាគមន៍

### ៣.២.២.១. ព័ត៌មានប្រជាសាស្ត្រ និងការយល់ដឹងទៅលើគម្រោងអភិវឌ្ឍន៍

ប្រជាសហាគមន៍ចំនួន៤៦នាក់បានចូលរួមផ្តល់បទសម្ភាស ស្តីពីការស្ទង់មតិសហាគមន៍ ហើយពួកគេមកពី៤៦[40]ទីតាំងផ្សេងគ្នា។ នៅក្នុងចំណោម៧៧ទីតាំង មានតែ៣១ទីតាំងដែលមិនអាចរកអ្នកចូលរួមដើម្បីធ្វើបទសម្ភាស។ ហេតុផលដែលមិនអាចរកអ្នកចូលរួមមកសម្ភាសបានគឺដោយសារមិនមានអ្នករស់នៅលើទីតាំងនោះ និងទីតាំងមួយចំនួនមានអ្នករស់នៅទីនោះខ្លះតែគេមិនមានឆន្ទៈក្នុងការចូលរួមក្នុងបទសម្ភាស (សូមមើលចំនុច២.២.២.ខ)។ ច្រើនជាងពាក់កណ្តាល (៥២%) នៃអ្នកចូលរួមគឺជាជនរងគ្រោះពីការបណ្តេញចេញ ហើយដែលគេបានត្រឡប់មករស់នៅលើទីតាំង ឬក្បែរទីតាំងធ្វើបទសម្ភាសចំណែកអ្នកដែលនៅសេសសល់គឺជាអ្នកដែលរស់នៅជិតទីតាំងដែលត្រូវគេបណ្តេញចេញ។ អាត្រានៃអ្នកចូលរួមរបស់ស្ត្រីមានទៅដល់៦១% ដែលច្រើនជាងចំនួននៃអ្នកចូលរួមជាបុរសដែលមានតែ៣៩%។ នៅក្នុងបទសម្ភាសនេះមានពីរក្រុមដែលមានអាយុសំខាន់ពីរគឺពី ២៥-៤០ឆ្នាំ (៣៧%) និងពី៥១-៨០(៣៧%)។ លើសពីនេះទៅទៀត អាត្រាអ្នកដែលបានមករស់នៅទីតាំងខាងលើ តិចជាងពាក់កណ្តាល (៤៥%) រវាងឆ្នាំ១៩៧៩-១៩៩០ (២៨%) ក្នុងកំឡុងឆ្នាំ ១៩៩១-២០០០ និង (២៨%) ក្នុងកំឡុងឆ្នាំ២០០២-២០១៦។

[40] Refer to Appendix 4 for the list of sites involved in the Community Survey.

| ពណ៌នា | ទីតាំងដែលគេបណ្តេញចេញទាំង៧៧ នៅក្នុងទីក្រុងភ្នំពេញ | |
|---|---|---|
| | ចំនួន | ភាគរយ(%) |
| **ក្រុមអាយុ** | | |
| ២០-៤០ | ១៧ | ៣៧ |
| ៤១-៥០ | ១២ | ២៦ |
| ៥១-៨០ | ១៧ | ៣៧ |
| **ភេទ** | | |
| ស្ត្រី | ២៨ | ៦១ |
| បុរស | ១៨ | ៣៩ |
| **ឆ្នាំនៃការមករស់នៅលើទីតាំង** | | |
| ១៩៧៩-១៩៩០ | ២០ | ៤៤ |
| ១៩៩១-២០០០ | ១៣ | ២៨ |
| ២០០២-២០១៦ | ១៣ | ២៨ |

***<u>តារាងទី២៖ ព័ត៌មានប្រជាសាស្ត្រ</u>***

អ្នកចូលរួមដែលជាបុរសភាគច្រើនជាអ្នកលក់ដូរ ឬធ្វើជំនួញដោយខ្លួនឯង ឬអ្នករត់ម៉ូតូឌុប ឬ អ្នករត់ម៉ូតូកង់បី។ ដោយឡែកអ្នកចូលរួមដែលជាស្ត្រីភាគច្រើន ពួកគេជាមេផ្ទះ និងខ្លះជាម្ចាស់ជំនួញខ្នាតតូច។

| មុខរបរ | បុរស | ស្ត្រី | ចំនួនសរុប |
|---|---|---|---|
| កម្មកររោងចក្រ | ០ | ១ | ១ |
| កម្មករសំណង់ | ០ | ១ | ១ |
| អ្នករត់ម៉ូតូឌុប ឬម៉ូតូកង់បី | ៤ | ០ | ៤ |
| បុគ្គលិកអង្គការ | ០ | ១ | ១ |
| មន្ត្រីរាជការ | ២ | ១ | ៣ |
| បុគ្គលិកក្រុមហ៊ុន | ១ | ១ | ២ |
| អ្នកប្រមូលសំរាម | ០ | ១ | ១ |
| មេផ្ទះ | ៣ | ១២ | ១៥ |
| អ្នកចូលនិវត្តន៍ | ០ | ២ | ២ |
| ជាងកាត់ដេរ | ០ | ១ | ១ |

| | | | |
|---|---|---|---|
| មេចុងភៅ | ២ | ០ | ២ |
| ម្ចាស់ជំនួញខ្នាតតូច | ៤ | ៧ | ១១ |
| គ្រូបង្រៀន | ១ | ០ | ១ |
| កម្មករ | ០ | ១ | ១ |
| **ចំនួនសរុប** | **១៧** | **២៩** | **៤៦** |

***តារាងទី៣៖ មុខរបររបស់អ្នកចូលរួមក្នុងកិច្ចសម្ភាស***

នៅពេលដែលសួរថា តើពួកគេធ្លាប់បានទទួលដំណឹងជាមុនពីការយកដីរបស់ពួកគេទៅអភិវឌ្ឍដែរឬទេ មាន៥៧%ឆ្លើយថាធ្លាប់ ៣០%អត់ច្បាស់ និង១៣%មិនដឹង។ នៅក្នុងចំណោម ៥៧%ដែលបានឆ្លើយថា ធ្លាប់ បានប្រាប់ថា អាជ្ញាធរជាអ្នកផ្តល់ព័ត៌មាន តែ ១៥%បានប្រាប់ថា ពួកគេបានទទួលដំណឹងពីអ្នកតំណាងរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ និង១២%ឆ្លើយថាពួកគាត់មិនច្បាស់ថាអ្នកដែលផ្តល់ព័ត៌មានឱ្យពួកគាត់ជាតំណាងរបស់ក្រុមណានោះទេ។ ក្នុងចំណោមអ្នកដែលដឹងថាដីរបស់ខ្លួនត្រូវបានគេយកទៅអភិវឌ្ឍ ៧៦%បានប្រាប់ថា ដីរបស់ពួកគេត្រូវបានគេយកទៅប្រើប្រាស់ដោយគោលបំណងផ្សេងៗ។ ដីរបស់ពួកគេត្រូវបានយកសម្រាប់ពង្រីកផ្លូវថ្នល់ (៣៨%) កសាងលំនៅដ្ឋាន (២១%) និងកសាងតំបន់ពាណិជ្ជកម្ម (១៧%)។ ចម្លើយរបស់អ្នកចូលរួមស្រដៀងគ្នាទៅនឹងលទ្ធផលនៃការស្ទង់មតិសង្កេតទីតាំង (នៅក្នុងចំណុច៣.២.១) ដែលបានរកឃើញនូវការអភិវឌ្ឍទាំងបីប្រភេទនេះ ដែលមាននៅស្ទើរគ្រប់ទីតាំងដែលបានធ្វើបទសម្ភាស។ ជាក់ស្តែង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធត្រូវបានគេផ្តល់អាទិភាពក្នុងគោលបំណងសម្រាប់សកម្មភាពពាណិជ្ជកម្ម។

បើទោះបីជាច្រើនជាងពាក់កណ្តាលនៃអ្នកចូលរួមបានប្រាប់ថា ពួកគេបានទទួលដំណឹងពីគម្រោងអភិវឌ្ឍន៍ មាន៩១%បានឆ្លើយថាពួកគេមិនច្បាស់ថាគម្រោងនោះបានអនុវត្តទៅតាមការគ្រោងទុក ឬយ៉ាងណានោះទេ។ លើសពីនេះទៅទៀត នៅពេលដែលសួរថា តើមានអ្វីខ្លះបានសាងសង់នៅលើតំបន់បណ្តេញចេញដែលពួកគេបានរស់នៅលើ ឬនៅក្បែរ ៤៧%បានប្រាប់ថាពួកគេអត់ដឹងច្បាស់នោះទេ។ បន្ថែមពីនេះទៅទៀតពេលដែលសាកសួរពីអ្នកទទួលខុសត្រូវលើការអភិវឌ្ឍ ៤១%បានឆ្លើយថា ក្រុមហ៊ុនឯកជន និង៣២%ប្រាប់ថាអត់ដឹងច្បាស់។ ហើយច្រើនជាងពាក់កណ្តាល (៥២%) បានឆ្លើយថា អាជ្ញាធរជាអ្នកទទួលខុសត្រូវចំពោះបណ្តេញចេញ។ តាមរយៈលទ្ធផលនៃការរកឃើញនេះ ទោះបីប្រជាសហគមន៍បានទទួលរងនូវការគំរាមកំហែងមុនការបណ្តេញចេញ និងទទួលដំណឹងនៃគម្រោងអភិវឌ្ឍន៍ទីតាំងក៏ដោយ ក៏ការចែករំលែកព័ត៌មានមានលក្ខណៈតិចតួច ឬក៏មិនបានជាសាធារណៈនោះទេ ។

កង្វះខាតតម្លាភាពនិងការផ្តល់ព័ត៌មានជាសាធារណៈនៅក្នុងឧទាហរណ៍ទាំងនេះ គឺជាភស្តុតាងដែលបានមកពីការឆ្លើយតបរបស់អ្នកចូលរួមក្នុងកិច្ចសម្ភាស។ កម្រិតនៃកង្វះខាតតម្លាភាពជាប្រព័ន្ធបានធ្វើឱ្យការអភិវឌ្ឍប្រព្រឹត្តិទៅដោយគ្មានការចូលរួមពីប្រជាពលរដ្ឋ ហើយវាជាបញ្ហាដែលតែងតែលើកឡើងដោយប្រជាសហគមន៍ ដែលប្រឈមមុខជាមួយនឹងការគំរាមកំហែងបែបនេះ។ ឧទាហរណ៍ នៅក្នុងសហគមន៍សាមគ្គី ៣.១ ដែលជាសហគមន៍រស់នៅតាមបណ្តោយផ្លូវរថភ្លើង កំពុងរងការគំរាមកំហែង។ លំនៅដ្ឋានខ្លះនៅទីនោះ ត្រូវបានលាបពណ៌ដោយថ្នាំពណ៌ក្រហមពីសំណាក់អាជ្ញាធរ ដើម្បីបញ្ជាក់ថាលំនៅដ្ឋាននោះនឹងត្រូវរុះរើចេញ។ ពួកគេមិនដែលទទួលបានការឆ្លើយតបពីអាជ្ញាធរឡើយ បន្ទាប់ពីប្រជាសហគមន៍មួយចំនួនបានទាក់ទងទៅសាលារាជធានីភ្នំពេញដើម្បីសុំធ្វើប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លី[41]។ ដូចគ្នានេះដែរ ក្នុងករណីសហគមន៍ប្លុកតាំប៉ា សាលារាជធានីភ្នំពេញបានប្រាប់ទៅប្រជាសហគមន៍នៅទីនោះថា អ្នកតំណាងមកពីសាលារាជធានីភ្នំពេញនឹងចុះទៅពិនិត្យទីតាំងផ្ទាល់ ហើយនឹងរៀបចំវេទិកាសាធារណៈ បន្ទាប់ពីមានការស្នើរសុំជាច្រើនលើកច្រើនសារពីសំណាក់ប្រជាពលរដ្ឋ។ ប៉ុន្តែ រហូតដល់ពេលនេះ អ្វីដែលសាលារាជធានីភ្នំពេញបានសន្យាមិនដែលកើតមានឡើយ។ លើសពីនេះទៅទៀត នៅក្នុងកិច្ចពិភាក្សាក្រុមជាមួយតំណាងសហគមន៍ទាំង៧នាក់ ដែលដឹកនាំដោយបុគ្គលិកអង្គការសមាគមធាងត្នោត ពួកគេបានបញ្ជាក់ថា ពួកគេធ្លាប់បានសាកសួរព័ត៌មានបន្ថែមទាក់ទងទៅផែនការនៃការបណ្តេញចេញរបស់រាជរដ្ឋាភិបាល។ អ្នកចូលរួមម្នាក់មកពីសហគមន៍ជ្រោយចង្វារបានស្នើសុំឱ្យមានវេទិកាសាធារណៈជាមួយនឹងអាជ្ញាធរមូលដ្ឋាន ដើម្បីរកមធ្យោបាយដ៏សមស្របណាមួយក្នុងការដោះស្រាយបញ្ហារបស់ពួកគេ។ ការស្នើសុំរបស់ពួកគេ នៅតែមិនមានការឆ្លើយតបមកទល់ពេលនេះ។ ការទទួលព័ត៌មានប្រកបដោយតម្លាភាពនៅតែជាបញ្ហាប្រឈមសម្រាប់ប្រជាសហគមន៍ ដោយសារតែប្រទេសកម្ពុជា ពុំមានអាជ្ញាធរថ្នាក់កណ្តាលមួយសម្រាប់ឱ្យប្រជាពលរដ្ឋស្នើសុំព័ត៌មាន និងការគាំទ្រពីពួកគាត់។

### ៣.២.២.២ ស្ថានភាពរស់នៅ និងការផ្លាស់ប្តូរស្ថានភាពសង្គមសេដ្ឋកិច្ចបន្ទាប់ពីការបណ្តេញចេញ ឬការអភិវឌ្ឍ

ក្នុងបទសម្ភាស អ្នកចូលរួមត្រូវបានសាកសួរអំពីផលប៉ះពាល់មកលើស្ថានភាពសង្គមនិងសេដ្ឋកិច្ចរបស់ពួកគេក្រោយការបណ្តេញចេញ ឬអភិវឌ្ឍន៍ ហើយលទ្ធផលនៃការឆ្លើយតបមានដូចខាងក្រោម[42]៖

[41] Samaki 3.1 (2015). Site visit to Samaki 3.1 and interview with resident, interviewed by Sahmakum Teang Tnaut, In Person, 19th June, 2015.
[42] The full spectrum of results is displayed in the appendix 5.

## ក. ស្ថានភាពនៃការរស់នៅ និងទីកន្លែងរស់នៅកាន់តែលំបាកទៅ

| ពណ៌នា | ការឆ្លើយតបកម្រិតខ្ពស់បំផុត (ភាគរយ) | | | ការឆ្លើយតបកម្រិតខ្ពស់ទី២ | | |
|---|---|---|---|---|---|---|
| | | បុរស | ស្រី | | បុរស | ស្ត្រី |
| ស្ថានភាពរស់នៅ | ប្រសើរឡើង (៣៩%) | ១២ | ៦ | ធម្មតា (៣០%) | ៥ | ៩ |
| បរិស្ថានជុំវិញទីកន្លែងរស់នៅ (អាក្រក់និងផ្សេង) | អាក្រក់ (៤៥%) | ១២ | ៩ | ធម្មតា (៣៤%) | ៥ | ១១ |
| ស្ថានភាពលំនៅដ្ឋាន | ធម្មតា (៤៣%) | ១០ | ១០ | អាក្រក់ (៣២%) | ១០ | ១០ |
| ទឹកជំនន់ | អាក្រក់ (៤៣%) | ១៣ | ៧ | ធម្មតា (២៣%) | ៣ | ៨ |
| ប្រាក់ចំណូល | ប្រសើរឡើង (៤១%) | ១១ | ៨ | អាក្រក់ (៣៤%) | ៧ | ៩ |
| សុវត្ថិភាពស្បៀង | អាក្រក់ (៥៨%) | ១៨ | ៩ | ធម្មតា (២៨%) | ៨ | ៥ |

***តារាងទី៩: ការឆ្លើយតបអំពីស្ថានភាពរស់នៅរបស់អ្នកចូលរួម***

មានសេចក្តីសន្និដ្ឋានពីរដែលអាចទាញចេញពីការរកឃើញនេះ។ ទី១មានការធ្លាក់ចុះនៃបរិស្ថានជុំវិញនៃកន្លែងរស់នៅរបស់ប្រជាសហគមន៍ ដែលពួកគេបានប្រាប់ថាស្ថានភាពរស់នៅជុំវិញតែងមានទឹកជំនន់ និងស្ថានភាពលំនៅដ្ឋានរបស់ពួកគេកាន់តែអាក្រក់ទៅ ឬមិនបានប្រសើរឡើងឡើយ។ លើសពីនេះទៅទៀត ដូចយើងឃើញក្នុងចំនុច៣.២.១ខាងលើ ៦៥%[43] នៃទីកន្លែងដែលបានសិក្សាស្រាវជ្រាវមិនត្រូវបានធ្វើការអភិវឌ្ឍពេញលេញនៅឡើយ គឺមានន័យថាអ្នកចូលរួមខ្លះស្នាក់នៅលើទីតាំង ឬនៅក្បែរការដ្ឋានសំណង់ ឬនៅលើទីតាំងដែលបានសម្អាត និងទុកចោល ដូចជាប្រជាសហគមន៍ដែលមកពីសហគមន៍ទួលស្វាយព្រៃនិងសហគមន៍៣៥[44]។ លទ្ធផលនេះ ក៏បានបង្ហាញអំពីកម្រិតនៃការអភិវឌ្ឍដ៏យឺតយ៉ាវដែលវាអាចជះឥទ្ធិពលដល់សុវត្ថិភាពស្បៀងអាហាររបស់ប្រជាសហគមន៍ ដូចជាការនេសាទ ឬការដាំដំណាំ ជាដើម។ ជាងពីរដងនៃចំនួនស្ត្រីបានរាយការណ៍ថា ផលប៉ះពាល់ដែលបណ្តាលមកពីសុវត្ថិភាពស្បៀងអាហារ គឺបង្ករឱ្យមានផលវិបាកដល់ស្ត្រីច្រើន ដោយសារពួកគេដើរតួរយ៉ាងសំខាន់ក្នុងការរៀបចំ ចម្អិន និងបែងចែកម្ហូបអាហារនៅក្នុងគ្រួសាររបស់គេ។ លើសពីនេះទៅទៀត ផលប៉ះពាល់នៃគ្រោះទឹកជំនន់ ដែលបណ្តាល

[43] 40% of the sites are partially developed and 35% have experienced no development.

[44] Refer to appendix 6 for a full list of site residents residing near eviction site.

មកពីការលុបបឹងដើម្បីអភិវឌ្ឍនេះ បានធ្វើឡើងនៅក្នុង២១ ទីតាំងក្នុងចំណោម៧៧ទីតាំង ដូចជាតំបន់បឹងកក់[45] ជាដើម។ ប្រជាពលរដ្ឋនៅជិតបឹងកក់បានប្រាប់ថា ចាប់តាំងពីការចាក់ខ្សាច់លុបបឹងមក លំនៅដ្ឋានរបស់ពួកគេបានរងផលប៉ះពាល់ដោយទឹកជំនន់[46]។ នៅក្នុងបទសម្ភាសជាមួយអង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង (UPWD) អ្នកស្រីបានបញ្ជាក់ថា ស្ត្រីជាច្រើនបានរងផលប៉ះពាល់ពីទឹកជំនន់ ដូចជា ប្រជាជននៅសហគមន៍ជ័យជំនះបានប្រឈមនឹងជម្ងឺឆ្លង និងជម្ងឺសើស្បែក ដែលបណ្តាលពីការប៉ះពាល់ទឹកមិនស្អាត។ ដូចគ្នានេះដែរកុមារតូចៗក៏ប្រឈមមុខនឹងជម្ងឺទាំងនេះដែរ ដោយសារពួកគេត្រូវដើរឆ្លងកាត់ទឹកកង្វក់ទាំងនេះដើម្បីទៅសាលារៀន និងប្រើប្រាស់ទឹកនោះ ដែលជាហេតុបណ្តាលឱ្យពួកគេមានជម្ងឺជាញឹកញាប់។ ដោយសារតែពុំមានផែនការក្នុងការអភិវឌ្ឍទីក្រុងឱ្យច្បាស់លាស់ ទើបនាំឱ្យមានការគ្រប់គ្រងការអភិវឌ្ឍមិនបានត្រឹមត្រូវ និងមិនបានកំណត់ទីតាំងច្បាស់លាស់[47]។ ទាំងបុរស ទាំងស្ត្រីដែលបានចូលរួមក្នុងកិច្ចសម្ភាសបានលើកឡើងថា ស្ថានភាពលំនៅដ្ឋានរបស់ពួកគេមិនមានភាពល្អប្រសើរឡើយ តែពួកគេយល់ថាលំនៅដ្ឋានរបស់គេប្រឈមមុខនឹងភាពគ្រោះថ្នាក់។

ស្ថានភាពរស់នៅ និងឱកាសរកប្រាក់ចំណូលមានភាពល្អប្រសើរជាងមុនបន្តិចបន្តួច។ សោភ័ណភាព និងលក្ខខណ្ឌទូទៅនៅក្នុងទីតាំងមួយចំនួនបានស្អាត និងល្អជាងមុន បន្ទាប់ពីការអភិវឌ្ឍ ហើយដោយសារតែឧបសគ្គ និងបញ្ហាប្រឈមនានាត្រូវបានដោះស្រាយ និងហេដ្ឋារចនាសម្ព័ន្ធត្រូវបានអភិវឌ្ឍ។ អាគារពាណិជ្ជកម្ម និងលំនៅដ្ឋានមានភាពប្រសើរឡើង ហើយជាពិសេសវាជួយបង្កើតការងារសម្រាប់ប្រជាសហគមន៍ ដែលរស់នៅតាមទីតាំងមួយចំនួន និងបង្កើននូវអតិថិជនដល់អ្នកលក់ដូរតូចតាច ឬហាងតូចៗផងដែរ ហើយនេះធ្វើឱ្យប្រជាពលរដ្ឋរស់នៅទីក្រុងមានជីវភាពល្អប្រសើរ។ លើសពីនេះទៅទៀត អាត្រានៃប្រាក់ចំណូលបានចាប់ផ្តើមកើនឡើង បើប្រៀបធៀបទៅនឹងការធ្លាក់ចុះនៃប្រាក់ចំណូលប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញ នៅក្នុងកំឡុងឆ្នាំ២០០០។ នៅឆ្នាំ២០១៤ អាត្រានៃប្រាក់ចំណូលសរុបជាមធ្យមប្រចាំខែគឺ ២,៨៥៦,០០០រៀល (៦៨៣ដុល្លារអាមេរិក)[48] ប្រៀបធៀបទៅនឹងឆ្នាំ២០០០ អាត្រានៃប្រាក់ចំណូលសរុបជាមធ្យមប្រចាំខែប្រមាណ ២,០៣៩,០០០រៀល[49] (៤៨៧ដុល្លារអាមេរិក)[50]។ នេះបង្ហាញពីការកើនឡើងនៃ ផលិតផលក្នុងស្រុកសរុប (GDP) នៅប្រទេសកម្ពុជា នៅក្នុងកំឡុងឆ្នាំ២០០៩ ទៅ២០១៤ ផលិតផលក្នុងស្រុកសរុបថ្នាក់ជាតិកើនឡើងពី១០.៦ពាន់លានដុល្លារអាមេរិក ទៅដល់ ១៤.៩ពាន់លានដុល្លារអាមេរិក[51]។

---

[45] Doyle, Shelby. (2012). *Phnom Penh City of Water*. Sahmakum Teang Tnaut, Phnom Penh, Cambodia, p. 10.
[46] The Cambodia Daily, (2009). Gov't Officials Stand Firm on Filling of Boeng Kak Lake
[47] *Op cit*.
[48] Converted using 2014 exchange rate as cited by Oanda - https://www.oanda.com/currency/converter/ [Accessed 1 Nov. 2016].
[49] National Institute of Statistics, Ministry of Planning, (2015). Cambodia Socio-Economic Survey 2014. [online] Phnom Penh, p.92. Available at: http://www.ilearnincambodia.net/uploads/3/1/0/9/31096741/cses_2014_report.pdf [Accessed 1 Nov. 2016].
[50] Converted using 2009 exchange rate as cited by Oanda.
[51] Databank.worldbank.org. (2016). World Development Indicators| World DataBank. [online] Available at: http://databank.worldbank.org/data/reports.aspx?source=2&country=KHM# [Accessed 1 Nov. 2016].

បើទោះបីជាមានការកើនឡើងផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា និងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅក្នុងមួយគ្រួសារក៏ដោយ ក៏វាចាំបាច់ត្រូវដឹងថាប្រជាសហគមន៍ក្រីក្ររស់នៅទីក្រុងត្រូវទទួលរងផលប៉ះពាល់ដោយការអភិវឌ្ឍ និងការបណ្តេញចេញ ហើយពួកគេមិនត្រូវបានរាប់បញ្ចូលនៅក្នុងទិន្នន័យខាងលើឡើយ ចំណែកកំណើនសេដ្ឋកិច្ចថ្នាក់ជាតិមិនបានជះឥទ្ធិពលដោយផ្ទាល់ទៅដល់ស្ថានភាពរស់នៅរបស់ពួកគេឡើយ។ តែផ្ទុយទៅវិញ ស្ទើរតែគ្រប់សហគមន៍ទាំងអស់ បានរាយការណ៍ថាប្រាក់ចំណូលរបស់ពួកគេបានប្រសើរឡើង ដោយសារពួកគេបានធ្វើជំនួញខ្នាតតូចរបស់គេនៅផ្ទះ ឬការងារក្រៅម៉ោងផ្សេងៗ។ បន្ថែមពីនេះទៅទៀតតាមរយៈការសម្ភាសជាមួយអង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង (UPWD) អ្នកស្រីបានប្រាប់ថានៅពេលដែលសាលារៀននៅជិតសហគមន៍ដែលគេរស់នៅ កុមារអាចធ្វើដំណើរទៅសាលារៀនដោយខ្លួនឯង ដែលនេះអាចចំណេញនូវការចំណាយលើមធ្យោបាយធ្វើដំណើរ។

ជាសរុបមក អ្នកដែលបានផ្តល់បទសម្ភាស ដែលមានស្ត្រី ច្រើនជាងបុរស បានប្រាប់ថាស្ថានភាពរស់នៅរបស់គេមានភាពប្រសើរឡើង។ តែស្ត្រីភាគច្រើន (១២នាក់ក្នុងចំណោម១៥នាក់នៃអ្នកដែលត្រូវបានសម្ភាស) បានបញ្ជាក់ថា ការងាររបស់គេគឺជា "មេផ្ទះ ឬស្នាក់នៅផ្ទះ" ដូច្នេះពួកគេដឹងពីផលប៉ះពាល់នានាដែលបណ្តាលពីកង្វះខាតហេដ្ឋារចនាសម្ព័ន្ធ ឬកត្តាគ្រោះថ្នាក់នានានៅជុំវិញកន្លែងរស់នៅរបស់គេ ដូចជា លូទឹកស្អុយដែលគ្មានគម្របជាដើម។

### ខ. ការទទួលបានសេវាសាធារណៈបានប្រសើរឡើង

| ពណ៌នា | ការឆ្លើយតបកម្រិតខ្ពស់បំផុត (ភាគរយ) | | | ការឆ្លើយតបកម្រិតខ្ពស់ ទី២ | | |
|---|---|---|---|---|---|---|
| | | បុរស | ស្ត្រី | | បុរស | ស្ត្រី |
| ការទទួលបានសេវាសុខភាព | ប្រសើរឡើង (៦៥%) | ១៧ | ១៣ | ធម្មតា (៣០%) | ៤ | ១០ |
| ការទទួលបានអគ្គិសនី | ប្រសើរឡើង (៣៩%) | ៨ | ១០ | ធម្មតា (៣៧%) | ៤ | ១៣ |
| ការទទួលបាននូវទឹកស្អាតប្រើប្រាស់ | ប្រសើរឡើង (៤៣%) | ៩ | ១១ | ធម្មតា (៣២%) | ១០ | ៥ |
| ការទទួលបានសេវកម្មប្រមូលសំរាម | អាក្រក់ (៣៤%) | ១១ | ៥ | ធម្មតា (៣២%) | ៨ | ៧ |

***តារាងទី៥ : ការឆ្លើយតបអំពីការទទួលបានសេវាសាធារណៈ និងសេវាសង្គម***

អ្នកដែលបានចូលរួមក្នុងកិច្ចសម្ភាសបានសម្តែងអារម្មណ៍ថា សេវាសាធារណៈ និងសេវាសង្គមមានភាពល្អប្រសើរ។ ដូចដែលពិភាក្សានៅក្នុងផ្នែកមុន ការអភិវឌ្ឍរួមមានការធ្វើឱ្យប្រសើរឡើងហេដ្ឋារចនាសម្ព័ន្ធ ដែលមានដូចជាការតម្លើង និងបង្កើនការតភ្ជាប់បណ្តាញអគ្គិសនី និងប្រព័ន្ធទឹកស្អាត។ ហើយដូចការបញ្ជាក់នៅចំនុច ៣.២.១ ការអភិវឌ្ឍបច្ចុប្បន្ន រួមមាន ការកសាងផ្លូវថ្នល់ មន្ទីរពេទ្យ ឬឧសថស្ថាននិងសាលារៀន ដោយជួយឱ្យមានការផ្តល់សេវាកម្មកាន់តែប្រសើរដែលមិនធ្លាប់មានពីមុននៅជិតទីកន្លែងផ្សេងៗ។ តែផ្ទុយទៅវិញវាជាការចំបាច់បំផុតក្នុងការយល់ឱ្យបានស៊ីជម្រៅពីលទ្ធផលជាក់ស្តែង។ ទោះបីជាការអភិវឌ្ឍបានបង្កើននូវសេវាផ្សេងៗក៏ដោយ ក៏វាមិនមែនជាការវិនិយោគដែលផ្តល់ប្រយោជន៍ផ្ទាល់ដល់ប្រជាសហគមន៍ ដែលបន្តរស់នៅលើទីតាំងដែលត្រូវបណ្តេញចេញឡើយ។ អ្នកចូលរួមក្នុងការសម្ភាសបានប្រាប់ថាពួកគេបានទទួលផលប្រយោជន៍ដោយប្រយោលពីការវិនិយោគនេះ ដោយសារពួកគេរស់នៅក្បែរទីតាំងអភិវឌ្ឍន៍ ដែលពីមុនមកមិនទាន់មានសេវាកម្មទាំងនេះនៅក្នុងសហគមន៍របស់ពួកគេ។

មានការឆ្លើយតបនៅក្នុងបទសម្ភាសទាក់ទៅនឹងសេវាកម្មប្រមូលសម្រាមថា សេវានេះនៅតែមិនទាន់ល្អនៅឡើយ។ ការប្រមូលសម្រាមនៅក្នុងរាជធានីភ្នំពេញ ជាបញ្ហាចម្រូងចម្រាស់មួយដោយសារសេវាកម្មប្រមូលសម្រាមត្រូវបានធ្វើឡើងដោយក្រុមហ៊ុនឯកជន (ស៊ីនទ្រី) ដែលផ្តល់សិទ្ធិដោយសាលារាជធានីភ្នំពេញនៅក្នុងឆ្នាំ២០០២។ សាលារាជធានីភ្នំពេញបានពិនិត្យ និងតាមដានជាបន្តបន្ទាប់ លើការចោទពីភាពអសកម្ម និងអសមត្ថភាពរបស់ក្រុមហ៊ុនស៊ីនទ្រី ក្នុងការដោះស្រាយបញ្ហាសម្រាមនៅតាមទីសាធារណៈ[52]។ របាយការណ៍មួយដែលចេញផ្សាយនៅក្នុងឆ្នាំ ២០០៦ ដោយអង្គការមូលនិធិអាស៊ី និងអូឌីអាយ (ODI) បានរកឃើញថា ៩០%នៃប្រជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញ មិនមានមធ្យោបាយប្រមូលសម្រាម[53] ដែលបង្កឱ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរលើបញ្ហាសម្រាមមានស្រាប់ ដែលបណ្តាលមកពីអាត្រាកើនឡើងនៃប្រជាជន និងការមករស់នៅទីក្រុងដ៏ច្រើនកុះករ។ ជាឧទាហរណ៍ នៅទីតាំងគេបណ្តេញចេញជាច្រើន ដូចជា សហគមន៍សាមគ្គី ៣.១ ប្រជាសហគមន៍ត្រូវបង្ខំចិត្តដុត ឬកប់សម្រាមនៅក្នុងសហគមន៍របស់ពួកគេ[54] តែម្តង។ លើសពីនេះទៅទៀត សេវាកម្មប្រមូលសម្រាមមិនទាន់មានឡើយនៅតំបន់ជាច្រើន ដោយសារផ្លូវចូលទៅសហគមន៍មានភាពតូចចង្អៀត ហើយវាពិបាកសម្រាប់ឱ្យឡានធំៗចូលទៅប្រមូលសម្រាម បើទោះបីជាប្រជាពលរដ្ឋបង់ប្រាក់ដើម្បីទទួលសេវានេះក៏ដោយ[55]។ ច្រើនជាងពីរដងនៃចំនួនស្ត្រីដែលបានចូលរួមក្នុងកិច្ចសម្ភាសបានប្រាប់ថា ការប្រមូលសំរាមមិនមានភាពល្អប្រសើរ នៅឡើយ។ ក្នុង

[52] Morn, Vanntey and De Carteret Daniel. (2016). *Trash Pact in Crosshairs*. Phnom Penh Post. Phnom Penh, Cambodia. Accessed via: http://www.phnompenhpost.com/national/trash-pact-crosshairs.

[53] Denney, Lisa. (2016). *Reforming Solid Waste Management in Phnom Penh.* The Asia Foundation. Phnom Penh, Cambodia.

[54] Samaki 3.1 (2015). Site visit to Samaki 3.1 and interview with resident, interviewed by Sahmakum Teang Tnaut, In Person, 19th June, 2015

[55] UPWD, (2016). Semi Structured Interview with UPWD, interviewed by Sahmakum Teang Tnaut, In Person, 28th October, 2016.

នាមជាមេផ្ទះ ស្ត្រីដើរបានតួរយ៉ាងសំខាន់ក្នុងការគ្រប់គ្រងអនាម័យ និងសម្អាតផ្ទះ របស់ពួកគេ ហើយពួកគេតែងតែប្រឈមនឹងការប៉ះពាល់ដល់សុខភាពដោយសារការគ្រប់គ្រង សំរាមមិនបានល្អ។ នៅពេលសម្ភាសជាមួយ តំណាងរបស់អង្គការអភិវឌ្ឍស្ត្រីក្រីក្រក្នុងទីក្រុង អ្នកស្រីបានបញ្ជាក់ថាការដែលបរិស្ថានជុំវិញក្នុងសហគមន៍មិនស្អាត វាបានជះឥទ្ធិពលអវិជ្ជមានដល់សុខភាពរបស់ប្រជាពលរដ្ឋ ជាពិសេស លើស្ត្រី និងកុមារ ដែលពួកគេអាចឆ្លងជំងឺផ្សេងៗ និងឈឺជាប្រចាំដោយសារសម្រាមទាំងនេះ[56]។

**គ. ផលប៉ះពាល់សង្គម និងទំនាក់ទំនងនៅក្នុងសហគមន៍មិនមានការប្រែប្រួល**

| ពិពណ៌នា | ការឆ្លើយតបកម្រិតខ្ពស់បំផុត (ភាគរយ) | | | ការឆ្លើយតបកម្រិតខ្ពស់ទី២ | | |
|---|---|---|---|---|---|---|
| | | បុរស | ស្ត្រី | | បុរស | ស្ត្រី |
| ទំនាក់ទំនងជាមួយអ្នកជិតខាង | ធម្មតា (៧៣%) | ១៣ | ២១ | អាក្រក់ (១៥%) | ៤ | ៣ |
| សាមគ្គីក្នុងសហគមន៍ | ធម្មតា (៨៣%) | ១០ | ១០ | អាក្រក់ (៣៧%) | ៦ | ១១ |
| ការចូលរួមក្នុងការអភិវឌ្ឍសហគមន៍ | ធម្មតា (៣៩%) | ១០ | ៨ | អាក្រក់ (៣៤%) | ៧ | ៩ |
| បណ្ដាញសុវត្ថិភាពសង្គម | អាក្រក់ (៨៣%) | ៧ | ១៣ | ធម្មតា (៣៩%) | ៨ | ១០ |
| ការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមគ្រួសារនៅស្រុកកំណើត | ធម្មតា (៧៦%) | ១២ | ២៣ | អាក្រក់ (២១%) | ៥ | ៥ |

*<u>តារាងទី៦: ការឆ្លើយតបអំពីការទទួលបាននូវការចូលរួមនៅក្នុងសង្គម</u>*

ទាក់ទងទៅនឹងផលប៉ះពាល់សង្គម អ្នកដែលចូលរួមក្នុងកិច្ចសម្ភាសបានបញ្ជាក់ថាមិនមានការប្រែប្រួលឡើយ។ អ្វីដែលជាការចាប់អារម្មណ៍ អ្នកដែលចូលរួមក្នុងកិច្ចសម្ភាស ភាគច្រើនគិតថាមិនមានផលប៉ះពាល់វិជ្ជបានកើតឡើងឡើយ។ ស្ត្រីជាច្រើនដែលបានចូលរួមក្នុងកិច្ចសម្ភាសបានសម្ដែងអារម្មណ៍ថា ការចូលរួមក្នុងសង្គមមិនមានការប្រែប្រួល ចំណែកសាមគ្គីភាពក្នុងសហគមន៍

[56] Ibid, page 28

ទាំងស្ត្រី ទាំងបុរសបានមានអារម្មណ៍ថាមិនមានការប្រែប្រួលឡើយ។ លើសពីនេះទៅទៀត អ្នកដែលចូលរួមសម្ភាសដែលរួមានអ្នកត្រឡប់មករស់នៅទីក្រុងវិញបន្ទាប់ពីការបណ្តេញចេញ និងអ្នកជិតខាងដែលរស់នៅតំបន់នោះបានសម្តែងពីការជុំរុញទឹកចិត្តក្នុងត្រឡប់មកវិញ ឬការមិនចង់ចាកចេញពីកន្លែងដែលគេធ្លាប់រស់នៅដោយសារវាមានសារៈសំខាន់ណាស់សម្រាប់ជីវភាពរបស់ពួកគេជាងលក្ខខណ្ឌផ្សេងៗ ដែលពួកគេបានព្រមទទួលយក។ ការទទួលបានអគ្គិសនី ឬបណ្តេញសុវត្ថិភាពសង្គម ប្រជាពលរដ្ឋបានត្រឡប់មករស់នៅជិតទីកន្លែងដែលគេធ្លាប់បណ្តេញចេញ ហើយពួកគេត្រូវបានគំរាមកំហែងឱ្យចាកចេញម្តងទៀត ប៉ុន្តែពួកគេត្រូវធ្វើបែបនេះដោយសារចង់ទទួលបានសេវាកម្មប្រសើរឡើង[57]។

នេះជាបញ្ហាដែលបានលើកឡើងដោយប្រជាសហគមន៍ក្រីក្ររស់នៅទីក្រុង ហើយដែលត្រូវបានបង្ខំឱ្យទៅរស់នៅទីកន្លែងផ្សេង ដោយសារការបណ្តេចចេញ។ ការបង្ខំឱ្យទៅរស់នៅទីតាំងថ្មី អាចប្រឈមមុខនូវការគំរាមកំហែងដល់និរន្តរភាពនៃជីវភាពរស់នៅរបស់ពួកគេ ដោយសារពួកគេមិនបានទទួលនូវសេវាកម្មល្អ មិនមានឱកាសក្នុងការបង្កើតប្រាក់ចំណូល និងមិនមានលំនៅដ្ឋានសមរម្យសម្រាប់ស្នាក់នៅ។ ឧទាហរណ៍ ប្រជាពលរដ្ឋមកពីតំបន់បឹងកក់ បានប្រាប់បុគ្គលិកអង្គការសមាគមធាងត្នោតថា ទីកន្លែងដែលគេទៅរស់នៅថ្មីនោះ ពុំមានសាលារៀននៅក្បែរផ្ទះរបស់គេឡើយ ដូច្នេះ កុមារមួយចំនួនត្រូវបង្ខំចិត្តបោះបង់ការសិក្សា[58]។

ដូចនេះ ប្រជាសហគមន៍ក្រីក្រដែលបន្តរស់នៅ ឬត្រឡប់មកទីកន្លែងដែលគេធ្លាប់រស់នៅក្នុងទីក្រុងវិញ អាចបានទទួលផលប្រយោជន៍ដោយប្រយោលពីការអភិវឌ្ឍ និងលម្ហិផលដែលគេបានបង្កើត ។ ផលប្រយោជន៍ដោយប្រយោលទាំងនេះដែលមិនមែនជាផ្នែកដ៏ធំក្នុងគម្រោងអភិវឌ្ឍ ឬនៅពេលណា តាមការរកឃើញស្ថានភាពរស់នៅរបស់អ្នកចូលរួម (ប្រជាជនក្រីក្រនៅក្នុងទីក្រុង) មិនបានប្រសើរឡើងឡើយ។ ជាឧទាហរណ៍ ប្រជាពលរដ្ឋពីសហគមន៍ស្ទឹងមានជ័យបានប្រាប់ពីការអភិវឌ្ឍគេហដ្ឋានរចនាសម្ព័ន្ធនៅក្នុងសហគមន៍របស់គាត់ (ក្នុងគោលបំណងជួយគាំទ្រដល់ការអភិវឌ្ឍពាណិជ្ជកម្ម) គឺជាមធ្យោបាយដើម្បីទប់ស្កាត់នូវបញ្ហាទឹកជំនន់ធ្ងន់ធ្ងរនៅក្នុងតំបន់នោះ[59]។

[57] LICADHO, (2016). Semi Structured Interview with LICADHO, interviewed by Sahmakum Teang Tnaut, In Person, 31st October, 2016.
[58] Forced Evictees, (2016). Focus Group Discussion with forced evictees, interviewed by Sahmakum Teang Tnaut, In Person, 21st October, 2016.
[59] Ibid

# ជំពូក ៤ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៤.១. សេចក្តីសន្និដ្ឋាន

គ្មាននណាម្នាក់មានចម្ងល់ឡើយអំពីផលប្រយោជន៍ដោយផ្ទាល់ ដែលបានមកពីការរីកចម្រើនទីក្រុងយ៉ាងឆាប់រហ័សបែបនេះ។ អាគារពាណិជ្ជកម្ម បុរីលំនៅដ្ឋាន និងការស្តារឡើងវិញនៃហេដ្ឋារចនាសម្ព័ន្ធដើម្បីស្វាគមន៍ការវិនិយោគ និងគម្រោងពាណិជ្ជកម្មនានា។ សេវារថយន្តក្រុងសាធារណៈបានចាប់ផ្តើមដំណើរការក្នុងរាជធានីភ្នំពេញក្នុងឆ្នាំ២០១៤ ហើយសេវាកម្មរថភ្លើងពីរាជធានីភ្នំពេញទៅខេត្តព្រះសីហនុត្រូវបានដាក់ឱ្យដំណើរការក្នុងដើមឆ្នាំ២០១៦។ ប៉ុន្តែ ការរីកចម្រើន និងការអភិវឌ្ឍទាំងនេះមានផលប៉ះពាល់ជាច្រើនដល់ប្រជាពលរដ្ឋរាប់រយរាប់ពាន់នាក់ ដែលត្រូវបានគេបណ្តេញដោយបង្ខំសម្រាប់ការអភិវឌ្ឍទាំងនេះ។ ៣៥%នៃទីតាំងទាំង៧៧ ត្រូវបានអភិវឌ្ឍទាំងស្រុងក្នុងរយៈពេលពីរទស្សវត្សនេះ ហើយសហគមន៍មួយចំនួនដូចជា សហគមន៍បឹងត្របែក និងសហគមន៍ជូលីណា[60] កំពុងរង់ចាំការអភិវឌ្ឍ។ ដូចនេះ វាអាចធ្វើសេចក្តីសន្និដ្ឋានថា ការបណ្តេញចេញក្រោមពាក្យការអភិវឌ្ឍ និងធ្វើទំនើបកម្មទីក្រុង គឺជាការសន្យាមិនសមរម្យ និងមានភាពទន់ខ្សោយនៅពេលដែលការអភិវឌ្ឍមានភាពយឺតយ៉ាវ។

លើសពីនេះទៅទៀត ផែនការអភិវឌ្ឍន៍នានារបស់អាជ្ញាធរ និងក្រុមហ៊ុនអភិវឌ្ឍន៍មិនមានតម្លាភាពសម្រាប់អ្នកត្រូវបានបណ្តេញចេញឡើយ។ ដូចដែលបានពិភាក្សាក្នុងផ្នែក ៣.២.២.១ សហគមន៍ក្រីក្រ និងសាធារណៈជនទូទៅ ជាធម្មតាមិនបានដឹងអំពីថាតើនរណាជាម្ចាស់កម្មសិទ្ធិនៃគម្រោងអភិវឌ្ឍន៍ នរណាជាអ្នកអនុវត្តគម្រោង ហើយពេលណាការសាងសង់នឹងចាប់ផ្តើម។ រាជរដ្ឋាភិបាលកម្ពុជាត្រូវបានគេមើលឃើញថាជាអ្នកដឹកនាំនៅពេលដែលអាជ្ញាធរមូលដ្ឋាន នគរបាល ឬយោធា ចេញសេចក្តីជូនដំណឹងស្តីពីការបណ្តេញចេញ ឬពាក់ព័ន្ធដោយផ្ទាល់នឹងការបណ្តេញចេញ។ បន្ថែមលើប្រព័ន្ធដែលមិនច្បាស់លាស់ វាក៏មានការខ្វះខាតរបស់ស្ថាប័នថ្នាក់កណ្តាល ដើម្បីទទួលខុសត្រូវក្នុងការដោះស្រាយជម្លោះប្រកបដោយប្រសិទ្ធភាពផងដែរ។ ក្នុងអំឡុងពេលកិច្ចសម្ភាស ដែលត្រូវបានរៀបចំឡើងដោយអង្គការសមាគមធាងត្នោតជាមួយតំណាងអង្គការលីកាដូ លោកបានលើកឡើងថាអាជ្ញាធរខ្វះគណនេយ្យភាព និងតម្លាភាព ដូចនេះហើយប្រជាសហគមន៍ក្រីក្រប្រឈមនឹងហានិភ័យខ្ពស់[61]។ ប្រជាសហគមន៍ត្រូវបានគៀបសង្កត់នៅពេលដែលពួកគេការពារសិទ្ធិដីធ្លីរបស់ពួកគេ ដូចជា ករណីសហគមន៍បុរីកីឡាដែលសាលារាជធានីភ្នំពេញបានប្រាប់

[60] Refer to Appendix 3 for the fill list of sites which are listed as “no development’.

[61] LICADHO, (2016). Semi Structured Interview with LICADHO, interviewed by Sahmakum Teang Tnaut, In Person, 31st October, 2016.

ពួកគេថា "ពួកគេនឹងមិនទទួលបាននូវអ្វីដែលពួកគេបានស្នើសុំឡើយ"[62] បន្ទាប់ពីពួកគេបានដាក់លិខិតទៅស្ថាប័នពាក់ព័ន្ធនានា។ ឧទាហរណ៍មួយផ្សេងទៀត សហគមន៍ជ្រោយចង្វាបានទាក់ទងទៅស្ថាប័នពាក់ព័ន្ធនានាជាច្រើនដង ដូចជាព្រឹទ្ធសភា រដ្ឋាភិបាល ខុទ្ទកាល័យនាយករដ្ឋមន្ត្រី និងអង្គការមិនមែនរដ្ឋាភិបាល។ ប្រជាសហគមន៍ក៏ស្នើសុំឱ្យមានការរៀបចំវេទិកាសាធារណៈដើម្បីស្វែងយល់ព័ត៌មានបន្ថែម[63]។ ករណីផ្សេងទៀត សហគមន៍មួយចំនួនទៀត(ដូចជា សហគមន៍ភូមិ ២៣) បានដាក់ញត្តិជាច្រើនទៅស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ (ដូចជា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សាលារាជធានីភ្នំពេញ និងស្ថាប័នអន្តរជាតិ ដូចជា ធនាគារពិភពលោក) ដើម្បីទាមទារសិទ្ធិទទួលបានព័ត៌មាន ប៉ុន្តែការខិតខំប្រឹងប្រែងរបស់ពួកគេត្រូវបានមើលរំលង និងព្រងើយកន្តើយ។

ប៉ុន្តែ ដំណោះស្រាយថ្មីមួយនៃ "ប៊ូលឌីង ឬអាគារស" គឺជាសូចនាករថ្មីមួយដោយករណី "គំរាមកំហែងនៃការបណ្តេញចេញ" ដែលត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដោយសារព័ត៌មានជាតិ ត្រូវបានដោះស្រាយដោយបើកចំហរ។ ប្រជាសហគមន៍បានជួបជាមួយនឹងតំណាងប្រធានភូមិកាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៦។ វាជាលើកដំបូងហើយតាំងពីសហគមន៍បានឮពាក្យចចាមអារាមនៃការបណ្តេញចេញកាលពីពីរឆ្នាំមុន។ ប្រជាសហគមន៍បានទទួលព័ត៌មានលម្អិតអំពីគម្រោងអភិវឌ្ឍន៍ដែលវិនិយោគដោយក្រុមហ៊ុនជប៉ុន អារ៉ាការ៉ា ហើយកិច្ចសន្ទនាដំបូងត្រូវបានរៀបចំឡើងជាមួយមន្ត្រីមកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិភាក្សាអំពីសំណង (ជាសាច់ប្រាក់ ឬទទួលយកផ្ទះនៅក្នុងអាគារប៊ូលឌីង)។ ប៉ុន្តែ ប្រជាពលរដ្ឋដែលរស់ក្នុងអាគារប៊ូលឌីងមានការព្រួយបារម្ភថា វាដូចទៅនឹងករណីបុរីកីឡាដែលក្រុមហ៊ុនផានអ៊ីមិចបានសន្យាសាងសង់អាគារចំនួន១០ដើម្បីផ្តល់ជូនសហគមន៍បុរីកីឡា។ មួយទសវត្សក្រោយមក ក្រុមហ៊ុនផានអ៊ីមិចបានសាងសង់ត្រឹមតែ៨អាគារប៉ុណ្ណោះ ហើយផ្តល់ឱ្យអ្នកដែលត្រូវបានបណ្តេញមួយចំនួនតែប៉ុណ្ណោះ។ ចំណែកឯប្រជាសហគមន៍រាប់រយនាក់ខ្វះលំនៅដ្ឋាន ហើយខាងក្រុមហ៊ុនផានអ៊ីមិចបានប្រកាសថាខ្វះថវិកាសម្រាប់សាងសង់អាគារចំនួន២ដែលបានសន្យា[64]។

ដូច្នេះ ដោយយោងទៅតាមការរកឃើញពីការស្ទង់មតិ កិច្ចសម្ភាស និងកិច្ចពិភាក្សាក្រុមដែលបានរៀបចំឡើងសម្រាប់ការសិក្សាស្រាវជ្រាវលើផលប៉ះពាល់នៃការអភិវឌ្ឍ ដែលបានសន្យាក្នុងទីតាំងទាំង៧៧។ លទ្ធផលបង្ហាញថា មានចំណុចជាច្រើនដែលត្រូវធ្វើដើម្បីឱ្យមានភាពប្រសើរឡើង។ អ្វីដែលបារម្ភបំផុតគឺអំពើហិង្សាដែលនៅតែបន្តកើតឡើង នៅពេលការអភិវឌ្ឍបែបនេះកើតឡើង។ សហគមន៍ក្រីក្រក្នុងទីក្រុង និងអ្នកដែលត្រូវបានគេបណ្តេញចេញមិនប្រឆាំងការអភិវឌ្ឍឡើយ។

[62] Forced Evictees, (2016). Focus Group Discussion with forced evictees, interviewed by Sahmakum Teang Tnaut, In Person, 21st October, 2016.
[63] Ibid.
[64] Narim, K. (2016). New Building, Broken Promises at Borei Keila. The Cambodia Daily. Retrieved from: https://www.cambodiadaily.com/news/new-building-broken-promises-at-borei-keila-113303/

ពួកគេយល់អំពីតម្រូវការនៃការអភិវឌ្ឍ និងទំនើបកម្មទីក្រុង ពីព្រោះក្នុងនាមជាអ្នករស់នៅក្នុងសហគមន៍ក្រីក្រ ពួកគេធ្លាប់មានបទពិសោធន៍ទទួលរងផលប៉ះពាល់ជាអវិជ្ជមាននៃខ្វះខាតនេះ។ ឧទាហរណ៍ ក្នុងអំឡុងពេលកិច្ចពិភាក្សាក្រុម អ្នកចូលរួមម្នាក់ដែលជាតំណាងមកពីសហគមន៍ស្ទឹងមានជ័យបានធ្វើសេចក្តីសន្និដ្ឋានថា "ការអភិវឌ្ឍគឺល្អ ប្រសិនបើរដ្ឋាភិបាលគោរពការសន្យារបស់ខ្លួន"។ ប៉ុន្តែ ពេលនេះអារម្មណ៍នៃភាពភ័យខ្លាច និងទុក្ខលំបាកបានផ្សារភ្ជាប់ទៅនឹងពាក្យថា អភិវឌ្ឍជន៍សម្រាប់អ្នកក្រក្នុងទីក្រុង។ តំណាងម្នាក់មកសហគមន៍ជ្រោយចង្វាបានលើកឡើងថា "អភិវឌ្ឍន៍គឺជាទឹកភ្នែករបស់ប្រជាពលរដ្ឋ"។

## ៤.២. អនុសាសន៍

នៅក្នុងបរិបទនៃការអភិវឌ្ឍទីក្រុងយ៉ាងឆាប់រហ័ស កំណើនប្រជាជន និងការកើនឡើងនៃការវិនិយោគឯកជន និងបរទេស ការបណ្តេញចេញនឹងកើតឡើងមិនអាចជៀសរួចឡើយ។ ទំនើបកម្ម និងការអភិវឌ្ឍគឺជាកត្តាលីករដ៏សំខាន់ ដែលរួមចំណែកក្នុងការលើកកម្ពស់ជីវភាពរស់នៅ និងចំណូលជាតិក្នុងប្រទេសកម្ពុជា។ ប៉ុន្តែ ការអភិវឌ្ឍ រូបនីយកម្ម ហើយនិងការបណ្តេញចេញ និងការតាំងទីលំនៅថ្មីរបស់ប្រជាសហគមន៍ក្រីក្រីគួរតែត្រូវបានអនុវត្តដោយច្បាប់ និងប្រកបដោយភាពត្រឹមត្រូវ និងសមធម៌ដើម្បីបង្កើតមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រកបដោយចិរភាព។ អង្គការសមាគមជាងត្នោត សូមផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោមដើម្បីឱ្យអ្នកពាក់ព័ន្ធនានា អនុវត្តក្នុងន័យដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់នានានៃការអភិវឌ្ឍន៍ ដូចដែលបានលើកឡើងក្នុងរបាយការណ៍នេះ៖

**រាជរដ្ឋាភិបាលកម្ពុជា៖**

1. អនុវត្តវិធីសាស្ត្រដោយឈរមូលដ្ឋានលើសិទ្ធិមនុស្ស ក្នុងការអនុវត្តកិច្ចការអភិវឌ្ឍនានាក្នុងរាជធានីភ្នំពេញ ក៏ដូចជាទូទាំងប្រទេសកម្ពុជា ហើយដើម្បីឱ្យស្របទៅនឹងការចាប់អារម្មណ៍ការវិនិយោគឯកជន និងវិស័យអចលនទ្រព្យ ដែលជាការកាតាលីករនាំឱ្យមានការអភិវឌ្ឍទីក្រុង។ ដូចដែលបានឆ្លុះបញ្ចាំងក្នុងគោលនយោបាយលំនៅដ្ឋាន និងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តអនុវត្តគោលការណ៍សិទ្ធិមនុស្ស និងធានាសិទ្ធិមានលំនៅដ្ឋានសមរម្យ និងការពារការរំខាននានាលើលំនៅដ្ឋានរបស់បុគ្គលណាម្នាក់ឡើយ។

2. អនុវត្តប្រកបដោយតម្លាភាព ដូចមានចែងក្នុង "ផ្នែកទី៣" ដំណាក់កាលទី៣នៃ យុទ្ធសាស្ត្រចតុកោណ៖ "ការបែងចែង និងប្រើប្រាស់ដីរដ្ឋបន្ថែម ជាពិសេស ការរឹបអូសដីសម្បទានសេដ្ឋកិច្ច និងសំអាតមីន តាមរបៀបមួយប្រកបដោយតម្លាភាព និងសមភាពសម្រាប់គោល

បំណងអភិវឌ្ឍន៍ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្រីក្រ....."[65]។ ជាងនេះទៅទៀតពង្រឹងកិច្ចខិតខំប្រឹងប្រែង និងបង្កើតមធ្យោបាយទទួលបានព័ត៌មាន ដូចជា កិច្ចពិគ្រោះយោបល់ជាសាធារណៈ នៅជំហ៊ានដំបូងជាមួយនឹងប្រជាសហគមន៍ដែលរស់នៅលើដីរដ្ឋ និងអ្នកពាក់ព័ន្ធដទៃទៀតដែលគ្រប់គ្រង និងវិនិយោគការអភិវឌ្ឍទីក្រុង។ ឧទាហរណ៍ ផែនការមេរាជធានីភ្នំពេញឆ្នាំ២០៣៥ ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១៥ គឺបានត្រឹមតែចែករំលែកដោយសង្ខេបតែប៉ុណ្ណោះ[66] ហើយមិនមានការពិគ្រោះយោបល់ជាសាធារណៈ ឬមានការចូលរួមពីអង្គការសង្គមស៊ីវិលក្នុងអំឡុងពេលកសាងផែនការអភិវឌ្ឍន៍នេះឡើយ។

3. អនុវត្ត និងបង្កើតនីតិវិធីប្រកបដោយភាពត្រឹមត្រូវ ឯករាជ្យភាព និងតម្លាភាពសម្រាប់អាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី (នីតិវិធីច្បាស់លាស់ និងផ្សព្វផ្សាយជាសាធារណៈស្តីពីដំណាក់កាលនានាដែលត្រូវបានប្រើប្រាស់ និងករណីដែលឆ្លងកាត់ការកាត់ក្តី និងមិនចាត់វិធានការដោយអាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី)។ ដាក់បញ្ចូលគោលនយោបាយទំនាស់ផលប្រយោជន៍ដែលត្រូវអនុវត្តរាល់ករណីធំៗទាំងឡាយ។
4. ចេញផ្សាយការផ្តល់សំណងគ្រប់គ្រាន់ និងយុត្តិធម៌ (ដូចដែលបានចែងក្នុងច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០១ ពាក្យថាសំណងសមរម្យ និងយុត្តិធម៌ត្រូវបានកំណត់ថា "ដូចនឹងតម្លៃទីផ្សារ ឬតម្លៃជំនួស" [67]។ ហើយ ដូចដែលមានចែងក្នុងមាត្រា ៥ ការផ្តល់សំណងគួរតែត្រូវបានផ្តល់ឱ្យមុនការបណ្តេញចេញ[68]។
5. វាយតម្លៃផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ដោយអនុលោមទៅតាមបទដ្ឋានអន្តរជាតិ និងសហការជាមួយសហគមន៍ដែលរងផលប៉ះពាល់មុនពេលអនុញ្ញាតិឱ្យមានគម្រោងអភិវឌ្ឍន៍នានាកើតមានឡើង។

**វិស័យឯកជន៖**

1. អនុវត្តបទដ្ឋាននានា ដូចជា គោលការណ៍ណែនាំរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ[69] (សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិដែលជាសមាជិកធនាគារពិភពលោក) ដែលតម្រូវឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ផ្តល់ព័ត៌មានទៅឱ្យអ្នកលក់ស្តីពីតម្លៃបច្ចុប្បន្នរបស់អចលនទ្រព្យ និងវិធីសាស្ត្រនៃ

---

[65] The Royal Government of Cambodia. (2013). The Rectangular Strategy Phase III. Phnom Penh, Cambodia, p.20.
[66] Phnom Penh Post. (2016). Phnom Penh's 2035 Master Plan in Minimal Use. Phnom Penh, Cambodia. Available at: http://www.phnompenhpost.com/post-property/phnom-penhs-2035-master-plan-minimal-use
[67] Office of The High Commissioner For Human Rights, (2012). Eviction and Resettlement in Cambodia: Human Costs, Impacts and Solutions. Phnom Penh, p.24. Retrieved from: http://cambodia.ohchr.org/sites/default/files/Thematic-reports/Resettlement_Study-28_Feb_2012_Eng.pdf
[68] MLMUPC Cambodia, (2002). Cambodian Land Law. Retrieved from: http://www.metheavy.com/File/Media/Land%20Law%202001.pdf
[69] IFC (International Finance Corporation). 2012. Guidance Note 5 – V2 Land Acquisition and Involuntary Resettlement. Washington, D.C: IFC.

ការវាយតម្លៃអចលនទ្រព្យ រួមទាំងផែនការតាំងទីលំនៅថ្មីដើម្បីឱ្យសមស្របទៅតាមបទដ្ឋានរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ប្រសិនបើអ្នកលក់នឹងបាត់បង់លំនៅដ្ឋានរបស់ពួកគេ ឬក្របខណ្ឌផ្តល់សំណងនៅពេលដែលជីវភាពរបស់ប្រជាសហគមន៍ប្រឈមនឹងហានិភ័យខ្ពស់។

2. អនុលោមទៅតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីអំពីធុរៈកិច្ច និងសិទ្ធិមនុស្ស[70] នៅពេលចាប់ផ្តើមអភិវឌ្ឍន៍ទីក្រុងក្នុងព្រះរាជណាចក្រកម្ពុជា។ ខណៈដែលរាជរដ្ឋាភិបាលមានតួនាទីរបស់ខ្លួនក្នុងការគោរពសិទ្ធិមនុស្ស វិស័យឯកជនត្រូវតែដឹងអំពីផលប៉ះពាល់នៃប្រតិបត្តិការរបស់ខ្លួនលើសិទ្ធិមនុស្ស តាមរយៈការវាយតម្លៃស្ថានភាពសិទ្ធិមនុស្ស (ឧទាហរណ៍ ពិភាក្សាជាមួយសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយការអភិវឌ្ឍរបស់ក្រុមហ៊ុន) ហើយបន្ទាប់មកចាត់វិធានការរឹងមាំនានា ដើម្បីគោរពសិទ្ធិរបស់អ្នកដែលទទួលរងផលប៉ះពាល់។

3. ផ្តល់នូវមធ្យោបាយ និងយន្តការសម្រាប់បណ្តឹងទាមទារជម្ងឺចិត្ត និងមានគណនេយ្យភាពសម្រាប់សហគមន៍ក្រីក្រក្នុងទីក្រុង នៅពេលដែលការអភិវឌ្ឍទីក្រុងរំលោភលើសិទ្ធិរបស់ពួកគេ។ យន្តការទាំងនេះត្រូវតែបង្ករភាពងាយស្រួលក្នុងការស្វែងរក មានតម្លាភាព មានប្រសិទ្ធភាព និងប្រសិទ្ធផល ហើយយន្តការទាំងនោះមិនគួរមានភាពយឺតយ៉ាវ ចំណាយលុយច្រើន ពិបាកស្វែងរកបាន ឬក្លែងបន្លំតាមរូបភាពពុករលួយឡើយ[71]។

**សហគមន៍អន្តរជាតិះ**

1. សហគមន៍អន្តរជាតិគួរតែត្រួតពិនិត្យដោយយកចិត្តទុកដាក់ និងធានាថាអាជ្ញាធររដ្ឋាភិបាលមានគណនេយ្យភាពក្នុងកិច្ចការពារ និងដោះស្រាយរាល់ការរំលោភបំពាននានាលើសុវត្ថិភាពដីធ្លី ការអភិវឌ្ឍដោយវិសមភាព និងការបែងចែកទីក្រុង។ ឧទាហរណ៍ កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) បានប្រកាសក្នុងឆ្នាំ២០១៦ បញ្ចប់គម្រោងសិទ្ធិដីធ្លីរបស់ខ្លួនដែលបានអនុវត្តអស់រយៈពេលជាង២០ឆ្នាំ ជាមួយនឹងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសារមានការមិនពេញចិត្តជាមួយនិងកំណែទម្រង់ដ៏យឺតយ៉ាវ[72]។ ប៉ុន្មានខែក្រោយមក ធនាគារពិភពលោកបានអនុម័តយល់ព្រមផ្តល់កម្ចីថ្មីចំនួន១៣០លានដុល្លាអាមេរិក ដល់រាជរដ្ឋាភិបាលកម្ពុជា ក្រោយពីបង្កកកម្ចីតាំងពីឆ្នាំ២០១១ ដែលការបង្កកនេះគឺជាទារុណកម្មលើរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងទៅនឹងការបណ្តេញចេញពីដីធ្លីដោយបង្ខំ។

[70] Business-humanrights.org. (2016). UN Guiding Principles | Business & Human Rights Resource Centre. Retrieved from: https://business-humanrights.org/en/un-guiding-principles
[71] Ibid., as outlined by the third pillar of the UN Guiding Principles on Business and Human Rights.
[72] Zsombor, P. (2016). In Frustration, Germany Ends Land Rights Work. The Cambodia Daily. Retrieved from: https://www.cambodiadaily.com/news/in-frustration-germany-ends-land-rights-work-107406/

កម្ចីចំនួន២៥លានដុល្លារសហរដ្ឋអាមេរិក ត្រូវបានបែងចែកសម្រាប់គម្រោងបែងចែកដីធ្លីសម្រាប់កិច្ចការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចដំណាក់កាលទី២[73]។

**សហគមន៍ក្រីក្រក្នុងទីក្រុង៖**

1. ពង្រឹងបណ្តាញសហគមន៍ក្រីក្រក្នុងទីក្រុង (អ្នកដែលត្រូវបានបណ្តេញចេញ និងអ្នកដែលកំពុងរស់ក្នុងការគំរាមកំហែងនៃការបណ្តេញចេញ) ដើម្បីបង្កើតមធ្យោបាយគាំទ្រ ចែករំលែកព័ត៌មាន និងផ្លាស់ប្តូរចំណេះដឹង។

2. សហគមន៍ងាយរងគ្រោះបំផុតនៅពេលដែលពួកគេមិនមានចំណេះដឹង។ ដូចនេះ អ្នកត្រូវស្វែងយល់អំពីសិទ្ធិស្របច្បាប់របស់អ្នក ស្ថានភាពសុវត្ថិភាពដីធ្លីបច្ចុប្បន្ន តម្លៃដីរបស់អ្នក ជំនួយផ្សេងៗនៅពេលដែលអ្នកចចារជាមួយអាជ្ញាធរ ឬក្រុមហ៊ុនអភិវឌ្ឍន៍ និងរៀបចំ និងថែរក្សាឯកសារស្របច្បាប់របស់អ្នក (សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិ ប្លង់ដីសហគមន៍ អត្តសញ្ញាណប័ណ្ណជាតិខ្មែរ)។ ការសិក្សាមួយរបស់ធនាគារពិភពលោកបានលើកឡើងថា បុរេនិច្ឆ័យសម្រាប់ការតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត៖ អ្នកលក់គួរតែ "យល់ដឹងអំពីសិទ្ធិរបស់គេ តម្លៃដីធ្លីរបស់ពួកគេ និងរបៀបចុះកិច្ចសន្យា និងមានជំនួយការក្នុងការវិភាគការវិនិយោគ ការចចារជាមួយវិនិយោគទុន ឃ្លាំមើលការអនុវត្ត និងធានាឱ្យមានការគោរពគោលការណ៍នានា" [74]។ ប៉ុន្តែ ការសិក្សាដូចគ្នានេះបានរកឃើញថា វិនិយោគិនចូលចិត្តធ្វើការជាមួយរដ្ឋណាដែលកំសោយផ្នែកអភិបាលកិច្ច និងកិច្ចការពារម្ចាស់ដីដែលងាយរងគ្រោះ[75]។

**សង្គមស៊ីវិល៖**

1. ផ្សព្វផ្សាយសេចក្តីណែនាំផ្នែកច្បាប់ទៅដល់សហគមន៍ក្រីក្រ និងសហគមន៍ងាយរងគ្រោះ ឬជនរងគ្រោះដោយការបណ្តេញចេញ និងអសន្តិសុខសុវត្ថិភាពដីធ្លី
2. ឃ្លាំមើល និងចងក្រងករណីនានាដែលរំលោភសិទ្ធិស្របច្បាប់ សិទ្ធិលំនៅដ្ឋានរបស់ប្រជាសហគមន៍ និងសិទ្ធិមនុស្ស ហើយនិងផ្តល់ការគាំទ្រ និងលើកឡើងករណីទាំងនេះជាមួយនឹងអាជ្ញាធរដែលពាក់ព័ន្ធ។

[73] Paviour, B. (2016). World Bank Will Resume Funding to Cambodia. The Cambodia Daily. Retrieved from: https://www.cambodiadaily.com/news/world-bank-will-resume-funding-to-cambodia-112866/
[74] World Bank, (2011). Rising Global Interest in Farmland: Can it Yield Sustainable and Equitable Benefits?. Agriculture and Rural Development. Washington DC: World Bank, p.XL Overview. Retrieved from: http://documents.worldbank.org/curated/en/998581468184149953/pdf/594630PUB0ID1810Box358282B01PUBLIC1.pdf
[75] STT notes the study was conducted by the World Bank in 2011, and the recent actions of unfreezing loans to Cambodia happened subsequently in 2016 (as mentioned in the prior section under 'International Community').

# ឧបសម្ព័ន្ធ

*<u>ឧបសម្ព័ន្ធ១៖ វិធីសាស្ត្រក្នុងការកំណត់សហគមន៍ដែល ទាំង៥ "មិនមានឈ្មោះ":</u>*

ផែនទីនៃទីតាំងបណ្តេញចេញទាំង៧៧ ក្នុងរាជធានីភ្នំពេញ ដែលផលិតដោយអង្គការសមាគមធាងត្នោត ក្នុងឆ្នាំ២០១១ បានដាក់បញ្ចូលទីតាំងចំនួន៥ ជា "ទីតាំងដែលគ្មានឈ្មោះ"។ ទិន្នន័យដែលបានប្រើប្រាស់សម្រាប់ការសិក្សាស្រាវជ្រាវក្នុងឆ្នាំ២០១១ គឺមិនមានគ្រប់គ្រាន់សម្រាប់ការសិក្សាស្រាវជ្រាវពេលនេះទេ ដូចនេះហើយ វាពិបាកក្នុងការប្រើប្រាស់ទិន្នន័យទាំងនេះសម្រាប់បញ្ជាក់ឈ្មោះ និងទីតាំងភូមិសាស្ត្រសហគមន៍ទាំង៥។ ដើម្បីកំណត់ទីតាំងសហគមន៍ទាំង ៥ សំណុំឯកសារចំនួន៣ត្រូវបានផលិតក្នុងកំឡុងពេលការសិក្សាស្រាវជ្រាវឆ្នាំ២០១១ និងផែនទីសហគមន៍ក្រីក្រក្នុងទីក្រុង ដែលផលិតដោយអង្គការសមាគមធាងត្នោតក្នុងឆ្នាំ២០០៨ ហើយក្នុងឆ្នាំ ២០១៤ ត្រូវបានវិភាគ និងត្រួតពិនិត្យ ដូចទៅនឹងទិន្នន័យដែលបានមកពីការស្ទង់មតិ៨ខណ្ឌរបស់អង្គការសមាគមធាងត្នោតក្នុងឆ្នាំ២០០៨ និងការសិក្សាស្រាវជ្រាវពីទីក្រុងភ្នំពេញដែលបានធ្វើក្នុងឆ្នាំ២០១៤។

ផែនទីចំនួនប្រាំត្រូវបានប្រើប្រាស់សម្រាប់ជាឯកសារយោង ក្នុងការសិក្សាស្រាវជ្រាវនេះ៖

- ផែនទីចង្អុលបង្ហាញពីទីតាំងរបស់សហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញ ដែលមាននៅក្នុងការស្ទង់មតិក្នុងខណ្ឌទាំង៨។
- ផែនទីឆ្នាំ២០១១ នៃទីតាំងបណ្តេញចេញទាំង៧៧ នៅក្នុងរាជធានីភ្នំពេញ
- ផែនទីសហគមន៍ដែលគេបណ្តេញចេញទូទាំងរាជធានីភ្នំពេញ ដែលត្រូវបានផលិតស្របពេលនឹងការសិក្សាឆ្នាំ២០១១
- ផែនទីសហគមន៍ដែលស្ថិតក្រោមការគំរាមកំហែងនៃការបណ្តេញចេញទូទាំងរាជធានីភ្នំពេញ ដែលត្រូវបានផលិតស្របពេលនឹងការសិក្សាឆ្នាំ២០១១
- ផែនទីចង្អុលបង្ហាញពីទីតាំងរបស់សហគមន៍ក្រីក្រក្នុងទីក្រុងភ្នំពេញ ដែលមាននៅក្នុងការស្ទង់មតិនៅក្នុងទីក្រុងភ្នំពេញ។

ការប្រៀបធៀបផែនទីចំនួន៣ ដែលផលិតក្នុងឆ្នាំ២០១១ បានលើកឡើងសហគមន៍ចំនួន៤ ដែលមានទីតាំង ដូចទៅនឹងទីតាំងដែលដាក់ថា "គ្មានឈ្មោះ" នៅក្នុងផែនទីនៃទីតាំងដែលត្រូវគេបណ្តេញចេញទាំង៧៧ ទីតាំង។ ទីតាំងទាំងនោះមានដូចជា បឹងកក់ភូមិ១ និងភូមិ៤ (ខណ្ឌទួលគោក)

ខាងក្រោយមណ្ឌលសុខភាព (ខណ្ឌទួលគោក) សង្កាត់បឹងកក់ (ខណ្ឌទួលគោក) និងសាមគ្គី (ខណ្ឌឬស្សីកែវ)។ ប្រៀបធៀបផែនទីក្នុងការសិក្សាស្រាវជ្រាវអំពីខណ្ឌទាំង៨ ផែនទីនៃការស្រាវជ្រាវពីទីក្រុងភ្នំពេញ និងផែនទីទីតាំងនៃតំបន់បណ្តេញចេញទាំង៧៧ ទីតាំង បានបង្ហាញថា ក្រុម៥៤ ស្ថិតនៅក្នុងទីតាំងទី៥។

